

DPA
DEVELOPMENT AND PARTNERSHIP IN ACTION

EAST WEST MANAGEMENT INSTITUTE
Porgram on Rights and Justice (PRAJ)

HIGHLANDERS ASSOCIATION-RATANAKIRI

I.C.S.O
Indigenous Community Support Organisation

CCiM
cambodian center for independent media

MY VILLAGE

CPN

NTFP
NON-TIMBER FOREST PRODUCTS ORGANIZATION

Y R D P

# សន្ទានុក្រមនៃពាក្យ

## ដែលប្រើនៅក្នុង

# ឧស្សាហកម្មនិស្សារណកម្មកម្ពុជា

EISEI បណ្តាញស្តីពីផលប៉ះពាល់សង្គម បរិស្ថានដោយឧស្សាហកម្ម និស្សារណកម្ម

## ឧសភា ២០១១

DPA
DEVELOPMENT AND PARTNERSHIP IN ACTION

# អារម្ភកថា

សទ្ទានុក្រមឧស្សាហកម្មនិស្សារណកម្ម គឺជាឯកសារដំបូងបំផុតដែលបានរៀបចំឡើង និងបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស។ សទ្ទានុក្រមនេះមានបំណងជួយដល់សមាជិកបណ្តាញ EISEI និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីយល់អំពីនិយមន័យនៃពាក្យដែលប្រើនៅក្នុងឧស្សាហកម្មនិស្សារណកម្ម និងដើម្បីជួយលើអ្នកដែលកំពុងធ្វើការសិក្សាស្រាវជ្រាវនៅក្នុងឧស្សាហកម្មនិស្សារណកម្ម និងវិស័យដែលពាក់ព័ន្ធ។

កម្ពុជាមានបរិស្ថានភូគព្ភសាស្ត្រ ដែលមានសក្តានុពលផ្ទុកនូវធនធានជាច្រើន ដូចជាបុកស៊ីត ទង់ដែង មាស ថ្មក្រានីត កៅឡាំង (kaolin) ថ្មកំបោរ ប៉ាហ្គូឌីត (pagodite) រំពុករុក្ខជាតិ ខ្សាច់និងគ្រួស ខ្សាច់ស៊ីលីកា ឈើបន្ទះ សំណប៉ាហាំង និងដីដែលសម្បូណ៌ទៅដោយសង្កសីជាដើម។

នៅក្នុងប្រទេសកម្ពុជា វិស័យឧស្សាហកម្មនិស្សារណកម្មមានលក្ខណៈថ្មី ហើយមានពាក្យបច្ចេកទេសគន្លឹះជាច្រើន។ បច្ចុប្បន្ននេះ គេនៅមានកង្វះខាតឯកសារជាភាសាខ្មែរដែលសរសេរអំពីវិស័យឧស្សាហកម្មនិស្សារណកម្ម ដោយហេតុថាវាគឺជាវិស័យថ្មីមួយ ហើយសទ្ទានុក្រមនេះត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការនេះ។ ទោះបីជាពាក្យដែលមាននៅក្នុងវចនានុក្រមនេះ មិនទាន់ត្រូវបានអនុម័តជាផ្លូវការក៏ដោយ ក៏បុគ្គលិករបស់លេខាធិការដ្ឋាន EISEI ជឿថាមានតម្រូវការបន្ទាន់សម្រាប់សៀវភៅនេះ ដែលអាចបម្រើជាឯកសារយោងបណ្តោះអាសន្នមួយដែរ។ នាពេលអនាគតយើងមានផែនការធ្វើបច្ចុប្បន្នកម្មសទ្ទានុក្រមនេះជារៀងរាល់ឆ្នាំ អាស្រ័យទៅលើបរិបទអភិវឌ្ឍន៍នៃឧស្សាហកម្មនិស្សារណកម្មនៅក្នុងប្រទេសកម្ពុជា។

បុគ្គលិកលេខាធិការដ្ឋាន EISEI ទទួលស្គាល់ថា គុណភាពសៀវភៅនេះអាចនៅមិនទាន់ល្អគ្រប់គ្រាន់នោះទេ ដូច្នេះ យើងសូមស្វាគមន៍រាល់មតិយោបល់ផ្សេងៗដើម្បីកែលម្អគុណភាពសៀវភៅនេះឲ្យកាន់តែប្រសើរថែមទៀត។ សូមផ្ញើមតិយោបល់មកកាន់លេខាធិការដ្ឋាន EISEI តាមរយៈអ៊ីមែល: eiseicoordinator@gmail.com

ឬតាមរយៈសំបុត្រមកកាន់អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA): អគារលេខ៦៩z, ផ្លូវលេខ៩៥០ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

បុគ្គលិកលេខាធិការដ្ឋានៈ

១. លោក ធី ទ្រី អ្នកសម្របសម្រួលបណ្តាញ EISEI,

២. កញ្ញា អ៊ីវ ច័ន្ទមុន្នីរ័ត្ន ជំនួយការអ្នកសម្របសម្រួលបណ្តាញ EISEI,

៣. លោក Jason D. Jones, ទីប្រឹក្សាបណ្តាញ EISEI

# សេចក្តីថ្លែងអំណរគុណ

បុគ្គលិកនៃលេខាធិការដ្ឋាន បណ្តាញស្តីពីផលប៉ះពាល់សង្គមបរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម (EISEI) សូមថ្លែងអំណរគុណដល់សហការីនៃអង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) ទាំងអស់ដែលបានពិនិត្យ និងផ្តល់យោបល់ដ៏មានតម្លៃចំពោះសៀវភៅនេះ ជាពិសេស លោក ម៉ម សម្បត្តិ នាយកប្រតិបត្តិអង្គការ DPA និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍របស់ EISEI។

បុគ្គលិកលេខាធិការដ្ឋាន EISEI សូមសម្តែងនូវអំណរគុណជាពិសេសដល់អ្នកឯកទេសទាំងឡាយដែលជាសមាជិកបណ្តាញ EISEI និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានពិនិត្យ និងផ្តល់យោបល់ ក៏ដូចជាដាក់បញ្ចូលនូវចំនុចសំខាន់ៗ ដែលក្នុងនោះរួមមាន៖ លោក ប៉ា ងួនទៀង នាយកប្រតិបត្តិមជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៃកម្ពុជា (CCIM), លោកស្រី ដាំ ចន្ទី នាយិកាប្រតិបត្តិសមាគមខ្មែរលើ, លោក ឡុង សេរី នាយកប្រតិបត្តិអង្គការអនុផលព្រៃឈើ (NTFP), លោក សៅ វណ្ណសី នាយកប្រតិបត្តិអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO), លោក គុំ អ៊ុយនីក មន្ត្រីកម្មវិធី ICSO, លោក ស៊ុន យ៉ូរ៉ា នាយកប្រតិបត្តិអង្គការភូមិខ្ញុំ (My Village MVI), លោក ឈាង សុខា នាយកប្រតិបត្តិនៃកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP), កញ្ញា ចាន់រ៉ាមី អ្នកសម្របសម្រួលផ្នែកឧស្សាហកម្មនិស្សារណកម្ម និងបម្រែបម្រួលអាកាសធាតុនៃអង្គការ YRDP និងលោកស្រី Terry Pernnel ទីប្រឹក្សាវិទ្យាស្ថានគ្រប់គ្រងបស្ចឹមបូព៌ា East West Management Institute (EWMI), លោក គឹម ហុង មកពី EWMI លោក ស្វាយ ភឿន មកពីបណ្តាញសន្តិភាពសហគមន៍ (CPN) លោកស្រី Gabi Yetter ទីប្រឹក្សាស្ម័គ្រចិត្តផ្នែកធនធានភាសាអង់គ្លេស DPA សមាជិកក្រុមការងារនៃឧស្សាហកម្មនិស្សារណកម្ម និងសមាជិកបណ្តាញ EISEI ។

បុគ្គលិកលេខាធិការដ្ឋាន EISEI សូមថ្លែងអំណរគុណដ៏ស្មោះចំពោះអង្គការ Oxfam អាមេរិក អង្គការ Trocairé, អង្គការជំនួយប្រជាជនន័រវេ (Norwegian

People's Aid-NPA), អង្គការ MISEREOR អង្គការអភិវឌ្ឍន៍ និងសន្តិភាព(D&P) ដែលបានផ្តល់ការគាំទ្រផ្នែកថវិកាសម្រាប់គម្រោងនេះ។

# សេចក្តីផ្តើម

កម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍមួយ ដូច្នេះការអភិវឌ្ឍប្រកបដោយចីរភាពអំពីធនធានធម្មជាតិគឺជាការចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេស។ ប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជា ពឹងផ្អែកលើធនធានធម្មជាតិដើម្បីគាំទ្រដល់ជីវភាពរបស់ពួកគេ។ ទោះបីជាយ៉ាងណាក្តី ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ជីវភាពនៅតំបន់ជនបទបានជួបប្រទះនឹងបញ្ហាប្រឈមកាន់តែច្រើនឡើង ដោយសារតែការធ្លាក់ចុះធនធានយ៉ាងរហ័ស។

ដើម្បីដោះស្រាយបញ្ហានេះ ជាពិសេសនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើវិស័យនេះ បានបង្កើតបណ្តាញមួយឈ្មោះថា បណ្តាញស្តីពីផលប៉ះពាល់សង្គមបរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម (EISEI) ក្នុងឆ្នាំ២០០៨ ដើម្បីធ្វើការជាក់លាក់ទៅលើផលប៉ះពាល់ពីសកម្មភាពជីករ៉ែ។ បណ្តាញ EISEI មានការិយាល័យស្ថិតនៅក្នុងអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) និងគ្រប់គ្រងដោយគណៈកម្មាធិការអចិន្ត្រៃយ៍មួយដែលមានសមាជិក៩រូប បោះឆ្នោតជ្រើសតាំងដោយសមាជិករបស់បណ្តាញ។ គណៈកម្មាធិការអចិន្ត្រៃយ៍បណ្តាញ EISEI បច្ចុប្បន្ន រួមមានតំណាងមកពី CCIM, CPN, DPA, EWMI, ICSO, HA, MVI, NTFP and YRDP.

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការពង្រីកអាជីវកម្មរុករក និងប្រតិបត្តិការរ៉ែនៅក្នុងប្រទេសកម្ពុជា បានកើនឡើងយ៉ាងរហ័ស ដូច្នេះបណ្តាញ EISEI បានសម្រេចចិត្តបោះពុម្ពផ្សាយសន្ទានុក្រមនេះ ដើម្បីបង្កើនការយល់ដឹងអំពីពាក្យបច្ចេកទេសនៅក្នុងឧស្សាហកម្មនិស្សារណកម្មជាភាសាខ្មែរ។

សន្ទានុក្រមនៃពាក្យបច្ចេកទេសសម្រាប់ឧស្សាហកម្មនិស្សារណកម្មនេះ ត្រូវបានសរសេរឡើងដោយប្រើភាសាសាមញ្ញ និង □ងាយយល់□។ គោលបំណងរបស់សៀវភៅនេះ គឺដើម្បីពន្យល់ពីពាក្យគន្លឹះភាគច្រើនបំផុតដែលគេប្រើនៅក្នុងឧស្សាហកម្មនិស្សារណកម្ម រួមទាំងវិស័យប្រេង និងឧស្ម័ន ពាក្យបច្ចេកទេសផ្នែកបរិស្ថាន និងឧស្សាហកម្មរ៉ែរឹងផងដែរ។ សៀវភៅសន្ទានុក្រមនេះនឹងត្រូវបាន

ប្រើប្រាស់ជាឯកសារយោង និងជាឧបករណ៍ដ៏មានតម្លៃសម្រាប់អង្គការសង្គមស៊ីវិល អង្គការជាសមាជិក EISEI សិស្ស/និស្សិត អ្នកស្រាវជ្រាវ និងអ្នកតាក់តែងគោលនយោបាយដែលត្រូវការពាក្យទាំងនេះ ជាទម្រង់សាមញ្ញដែលងាយយល់បាន។

សៀវភៅនេះមិនមែនជាឯកសារលម្អិតពេញលេញនោះទេ។ ដូច្នេះ យើងខ្ញុំសូមលើកទឹកចិត្តសមាជិកដទៃទៀត អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធធ្វើបច្ចុប្បន្នកម្មបន្ថែមទៀត សម្រួលពាក្យឲ្យសាមញ្ញ និងដាក់បញ្ចូលពាក្យបច្ចេកទេសបន្ថែមទៀតដែលប្រើនៅក្នុងឧស្សាហកម្មនិស្សារណកម្ម។

# A

**បោះបង់** (Abandon)៖ បញ្ឈប់ផលិតកម្មជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ពីអណ្តូងរ៉ែ ឬបញ្ឈប់ប្រតិបត្តិការខួងរ៉ែទៅមុខទៀត។

**ការបង្ហូររ៉ែអាស៊ីដ** (Acid mine drainage)៖ នៅពេលថ្មមានជាតិស៊ុលហ្វ័រប៉ះនឹងខ្យល់ និងទឹក (ដូចជាជាតិស៊ុលហ្វ័រនៅព័ទ្ធជុំវិញស្រទាប់រ៉ែមាសប្រាក់ និងទង់ដែងជាដើម) អាស៊ីដស៊ុលហ្វ័រិកក៏ត្រូវកើតឡើង។ អាស៊ីដនេះរំលាយលោហធាតុធ្ងន់ៗដែលឃើញមាននៅក្នុងថ្មសំណល់ និងសំណល់ពីការកែច្នៃរ៉ែមាសដែលត្រូវបង្កើតឡើងនៅអំឡុងពេលប្រតិបត្តិការនិស្សារណកម្មរ៉ែ។ ល្បាយគីមីពុលនេះក៏ហូរចូលទៅក្នុងដី និងទឹកលើផ្ទៃដី។

**ការតស៊ូមតិ**(Advocacy)៖ អនុសាសន៍ ការគាំទ្រ និងការជំរុញគោលនយោបាយ ឬវិធានការផ្លាស់ប្តូរដទៃទៀត។ ការគាំទ្រមតិអាចធ្វើឡើងដោយក្រុមសង្គមស៊ីវិល និងផ្នែកឯកជននានារួមមានដូចជាសម្ពាធបរិស្ថាន និងក្រុមជាប់ផលប្រយោជន៍ដទៃទៀតសហគមន៍ឥណទាននៅមូលដ្ឋានសហជីពក្រុមសហគមន៍ និងក្រុមហ៊ុនជាដើម។

**ជលសិលា** (Aquifer) ៖ បរិមាណកំហាប់ទឹកក្រោមដីដែលគេឃើញមាននៅក្នុងស្រទាប់ថ្មជ្រាបទឹក។

**សំលោហៈ** (Alloy) ៖ ល្បាយនៃលោហធាតុពីរ ឬច្រើន តាមធម្មតាកើតឡើងដោយដំណើររំលាយចូលគ្នា។

**ល្បប់** (Alluvial) ៖ រួមមានកំណរ៉ែជាទម្រង់ណាមួយ ក្រៅពីកំណរ៉ែកាបូណាតដែលមិនស្ថិតនៅក្នុងនិយមន័យ □ស្រទាប់លោហៈក្នុងដី□ (lode)។

**សិលាង្គារ** (Anthracite)៖ ធ្យូងថ្មដែលមានទម្រង់រឹងបំផុត និងមានប្រសិទ្ធភាពបំផុតមានសារធាតុកាបូនខ្ពស់បំផុត និងមានចំណុះទឹកទាបបំផុត។ (សូមមើលពាក្យធ្យូងថ្មផងដែរ)។

**ឥន្ធនៈជំនួស** (Alternative Fuel)៖ គេអាចហៅម៉្យាងទៀតថាឥន្ធនៈខុសពីធម្មតា

ឬទំនើប។ ឥន្ធនៈជំនួសគឺជាវត្ថុធាតុឬសារធាតុដែលអាចប្រើជាឥន្ធនៈក្រៅពីឥន្ធនៈធម្មតា។ ឥន្ធនៈជំនួសដែលគេស្គាល់រួមមាន ជីវៈម៉ាស៊ូត ជីវអាលកុល (មេតាណុល អេតាណុល ប៊ូតាណុល) អគ្គិសនីបន្ទុកគីមី (ដូចជា អាគុយនិងបន្ទុកឥន្ធនៈជាដើម) [GreenNH3] មិនមែនផូស៊ីលអ៊ីដ្រូហ្សែន មេតានមិនមែនផូស៊ីល ឧស្ម័នធម្មជាតិមិនមែនផូស៊ីល ប្រេងបន្លែ ព្រមទាំងប្រភពជីវម៉ាសដទៃទៀត។

**សិប្បកម្មរ៉ែ** (Artisanal Mining)៖ ការជីករករ៉ែដោយបុគ្គលម្នាក់ ឬមនុស្សមួយក្រុមដែលធ្វើអាជីវកម្មទាញយកស្រទាប់រ៉ែដូចជាសំណប៉ាហាំង និងមាសដោយប្រើប្រាស់បច្ចេកវិទ្យាសាមញ្ញបំផុតដូចជាឧបករណ៍ដោយដៃផ្ទាល់ឬអាចកាន់នឹងដៃបាន។ សិប្បកម្មរ៉ែ តាមធម្មតា គឺជាសកម្មភាពគ្រាន់តែដើម្បីចិញ្ចឹមជីវិតប៉ុណ្ណោះ ដែលជារឿយៗធ្វើឡើងតាមរដូវកាល។

**សវនកម្ម** (Audit)៖ គឺជាដំណើរការទទួល ផ្ទៀងផ្ទាត់ អាចពាក់នឹងការសម្រួល និងរាយការណ៍អំពីព័ត៌មាន រួមមានដូចជានៅក្នុងបរិបទ EITI, ទាក់ទងនឹងព័ត៌មានហិរញ្ញវត្ថុ ឬរូបវន្តដែលពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម។

# B

**បារ៉ែល** (Barrel)៖ ខ្នាតចំណុះប្រេងឆៅដែលគេប្រើប្រាស់នៅក្នុងឧស្សាហកម្មប្រេងឥន្ធនៈ ជាពិសេសនៅសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។ ការប្រើប្រាស់ខ្នាតចំណុះនេះមានតាំងពីសម័យធ្វើដំណើរដោយសំពៅនៅពេលដែលប្រេងឥន្ធនៈត្រូវដឹកជញ្ជូនក្នុងធុងម្លេះ។

**លោហៈបាស** (Base Metal)៖ គឺជាលោហៈដែលមានលក្ខណៈសាមញ្ញ និងមិនត្រូវចាត់ទុកថា មានតម្លៃឬកម្រតាមធម្មតាវត្ថុរឹងភ្លឺរលោងដែលចម្លងកម្ដៅ ឬអគ្គិសនី និងអាចបង្កើតបានជាទម្រង់សន្លឹកផ្សេងៗ។ ឧទាហរណ៍ដូចជា សំណ ដែក ទង់ដែង សំណប៉ាហាំង និងស័ង្កសីជាដើម។

**បុកស៊ីត** (Bauxite)៖ ថ្មល្បប់នៃរ៉ែអាលុយមីញ៉ូមនេះត្រូវគេប្រើប្រាស់ដើម្បីធ្វើជាអាលុយមីញ៉ូម។ រ៉ែបុកស៊ីតត្រូវគេធ្វើនៅក្នុងរណ្ដៅរ៉ែចំហ។ ទឹកនៅក្នុងបុកស៊ីតត្រូវបំបែកចេញពីរ៉ែដែលផលិតបានជាម្សៅពណ៌សម្យ៉ាងហៅថា អាលុយមីណា

(ឬអាលុយមីញ៉ូមអុកស៊ីត)។ អាលុយមីណាត្រូវធ្វើឲ្យទៅជាអាលុយមីញ៉ូម ហើយត្រូវបានគេប្រើនៅក្នុងស៊ីម៉ង់ត៍សារធាតុគីមី គ្រឿងតុបតែងមុខ កំប៉ុងស្ងួជាសាប៊ូលាងចាន ជញ្ជាំងផ្ទះ និងផលិតផលអាលុយមីញ៉ូមជាច្រើនទៀត។ ការចម្រាញ់អាលុយមីណាពីបុកស៊ីតត្រូវចំណាយច្រើនណាស់ ដូច្នេះការធ្វើរ៉ែបុកស៊ីតមានតែធ្វើឡើងជាទ្រង់ទ្រាយធំប៉ុណ្ណោះ។

**ការទាញយកប្រយោជន៍** (Beneficiation)៖ ១)ដំណើរការមួយចំនួនដែលរ៉ែដែលត្រូវបានគេចម្រាញ់ចេញពីការជីករ៉ែ ត្រូវបានបំបែកចូលទៅក្នុងរ៉ែ និងដីជាប់នឹងរ៉ែដែលដើមឡើយមានលក្ខណៈសមស្របសម្រាប់ការកែច្នៃបន្ថែម ឬប្រើប្រាស់ដោយផ្ទាល់។ ២)ពាក្យនេះក៏ត្រូវប្រើដើម្បីពណ៌នា ជាការប្រៀបធៀបសមាមាត្រនៃតម្លៃដែលបានមកពីការធ្វើអាជីវកម្មអចលនទ្រព្យនៅក្នុងប្រទេស និងផលប្រយោជន៍ចំពោះសហគមន៍មូលដ្ឋានផងដែរ។

**ជីវឥន្ធនៈ** (Bio-fuel)៖ គឺជាឥន្ធនៈដែលមានទម្រង់ជាវត្ថុរាវរឹង ឬឧស្ម័នដែលត្រូវចម្រាញ់ទាំងមូល ឬជាផ្នែកចេញពីសារធាតុជីវសាស្ត្រប្រកបដោយនិរន្តរភាពដែលតាមធម្មតាជារុក្ខជាតិ។

**ធ្យូងថ្មខ្មៅ** (Black coal)៖ ជាប្រភេទធ្យូងថ្មដ៏មានប្រសិទ្ធភាពបំផុតដែលនៅក្នុងនោះមានផ្ទុកបរិមាណទឹកតិចជាងធ្យូងថ្មពណ៌ត្នោត ជាហេតុនាំឲ្យវាផ្តល់ជាថាមពលច្រើនជាងធ្យូងថ្មពណ៌ត្នោត។ (សូមមើលពាក្យថាធ្យូងថ្មនិងធ្យូងថ្មពណ៌ត្នោត)។

**ការបំផ្ទុះ** (Blasting)៖ គឺជាដំណើរការមួយដែលគេប្រើដើម្បីបង្កើត/ឆ្កា ឬជម្រះតំបន់ទីតាំងធំមួយ ឬដើម្បីបំបែកថ្មនៅក្នុងរយៈពេលដ៏ខ្លីដោយប្រើគ្រឿងផ្ទុះតាមធម្មតាគឺល្បាយសារធាតុគីមី។

**ការបង្ហូតអណ្តូងរ៉ែ** (Blowing a Well): ការបើកចំហអណ្តូងរ៉ែដើម្បីឲ្យវាហូតមួយរយៈពេលខ្លីដើម្បីឲ្យអណ្តូងនោះស្ងួតទឹក ឬរងទឹក ខ្សាច់ និងកំណកដទៃទៀតដែលដក់ក្នុងអណ្តូង។

**អណ្តូងខួង** (Borehole)៖ រន្ធឬអណ្តូងនៅក្នុងដីធ្វើឡើងដោយការខួងអណ្តូងខួង

ចំហារចេញពីផ្ទៃដីចូលទៅដល់បាតអណ្តូង។

**អណ្តូងធំ** (Borrow)៖ រណ្តៅចំហធំឬរន្ធធំដែលតាមរយៈរន្ធនេះគេធ្វើនិស្សារណកម្មរ៉ែចេញពីផ្ទៃដី។

**រន្ធបាតអណ្តូង** (Bottom Hole)៖ ផ្នែកក្រោមឬជ្រៅបំផុតនៃអណ្តូងមួយ។

**ធ្យូងថ្មពណ៌ត្នោត** (Brown coal)៖ ជាប្រភេទធ្យូងថ្មម៉្យាងហៅម៉្យាងទៀតថាធ្យូងថ្មលីនីតដែលមានសភាពទន់ជាងធ្យូងថ្មពណ៌ខ្មៅ មានចំណុះកាបូនទាបជាង និងមានចំណុះទឹកខ្ពស់ជាងធ្វើឲ្យវាមានប្រសិទ្ធិផលតិចជាង ធ្យូងថ្មពណ៌ខ្មៅ។ ដូចជាឥន្ទនៈដែរធ្យូងថ្មពណ៌ត្នោតជា ទម្រង់ធ្យូងថ្មដែលមានលក្ខណៈបំពុលខ្ពស់បំផុត ដោយបង្កើតជារំភាយឧស្ម័នផ្ទះកញ្ចក់កម្រិតខ្ពស់បំផុត។ (សូមមើលពាក្យធ្យូងថ្មផងដែរ)។

# C

**ទ្រុង** (Cage)៖ យានដឹកជញ្ជូនដែលគេប្រើសម្រាប់ដឹកជញ្ជូនមនុស្ស និងឧបករណ៍នៅក្នុងអណ្តូងរ៉ែ។

**បំណុលកាបូន** (Carbon Debt)៖ ការប្រើប្រាស់ហួសកម្រិតដោយបុគ្គល ឬរដ្ឋនូវសមត្ថភាពស្រូបយកកាបូនឌីអុកស៊ីដរបស់មហាសមុទ្ររុក្ខជាតិ និងដីនៅក្នុងពិភពលោក។

**ធ្យូងថ្ម** (Coal)៖ គឺជាថ្មដែលមានចំហេះនៃដើមកំណើតសរីរាង្គដែលមានសមាសភាគចម្បងទៅដោយកាបូន (៥០-៩៨ភាគរយ), អ៊ីដ្រូហ្សែន(៣-១៣ភាគរយ) និងអុកស៊ីហ្សែនដែលមានបរិមាណនីត្រូហ្សែនតិចច្រើនជាងស៊ុលហ្វ័រ និងអង្គធាតុដទៃទៀត។ ធ្យូងថ្មត្រូវបង្កើតឡើងដោយចុណ្ណភាគ ដើម្បីបំពេញការបំបែកធាតុរុក្ខជាតិកាបូនកម្មក្រោមសម្ពាធរាប់ពាន់ឆ្នាំកន្លងទៅ។ ជានិច្ចកាលតែងតែមានវត្តមានទឹកខ្លះៗជាគ្រាប់សារធាតុអសរីរាង្គ ដែលបង្កើតបានជាសំណល់គ្មានចំហេះដូចជាផេះជាដើម។

ធ្យូងថ្ម ត្រូវបែងចែកតាមឋានានុក្រមអាស្រ័យតាមបរិមាណកាបូនដែលមាន

វត្តមាន ដូចមានបង្ហាញទៅតាមដំណាក់កាលវិវត្តន៍របស់វាពីដំណាក់កាលរំពុករុក្ខជាតិដំបូងរហូតក្លាយជាធ្យូងថ្មពណ៌ត្នោត (ធ្យូងថ្មលីនីត/lignite) ធ្យូងថ្មមានចំហេះទាប និងសិលាង្គារ។ សិលាង្គារ ឬធ្យូងថ្មសិលាង្គារដែលកើតចេញពីថ្មបំឡែងខ្លួន គឺជាធ្យូងថ្មដ៏រឹងបំផុតនិងមានផ្ទុកកាបូនច្រើនបំផុត។ ធ្យូងថ្មមានចំហេះកើតឡើងពីថ្មកំណក។

ធ្យូងថ្មមានចំហេះទាបធ្យូង មានចំហេះនិងសិលាង្គាររួមគ្នាហៅថា ធ្យូងថ្មពណ៌ខ្មៅហើយមានឥន្ធនៈប្រសើរជាងធ្យូងថ្មពណ៌ត្នោត។

ធ្យូងថ្មពណ៌ត្នោតដែលហៅម៉្យាងទៀតថាធ្យូងថ្មលីនីតនេះ មានសភាពទន់ជាងធ្យូងថ្មពណ៌ខ្មៅ និងមានចំណុះកាបូនទាបជាងនិងចំណុះទឹកខ្ពស់ជាង។ វាមានបរិមាណឥន្ធនៈប្រមាណជា ២៥% ធៀបនឹងធ្យូងថ្មពណ៌ខ្មៅ។ វាជាសារធាតុទន់ដែលមានបរិមាណកម្តៅត្រឹមតែមួយភាគបួន នៃបរិមាណកម្តៅរបស់ធ្យូងថ្មពណ៌ខ្មៅប៉ុណ្ណោះ។

ជាប្រភពថាមពលមួយធ្យូងថ្មមានលក្ខណៈបំពុលខ្ពស់ និងបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន។ ធ្យូងថ្មពណ៌ត្នោតកាន់តែអាក្រក់ជាងធ្យូងថ្មពណ៌ខ្មៅទៅទៀត បើនិយាយអំពីរ៉ែធ្យូងថ្ម៖ ផ្ទៃដីព្រមទាំងរចនាសម្ព័ន្ធបរិក្ខារគ្រឿងចក្រឧបករណ៍សម្ភារៈអណ្តូងទីចំណោតផ្លូវក្រោមដីការជីកកាយដី និងទ្រព្យទាំងរូបី និងទាំងផ្ទាល់ខ្លួនដែលផ្ទុកពីលើក្រោម ឬពីផ្ទៃដីនៃផ្ទៃដីនោះដោយបុគ្គលណាម្នាក់ និស្សារណកម្មធ្យូងថ្មពីស្រទាប់រ៉ែធម្មជាតិរបស់វានៅក្នុងដីដោយមធ្យោបាយ ឬវិធីសាស្ត្រ និងការងាររៀបចំធ្យូងថ្ម ដែលបានធ្វើនិស្សារណកម្មរាប់បញ្ចូលទាំងបរិក្ខាររៀបចំធ្យូងថ្មផងដែរ។

**កូបាល់ត៍** (Cobalt)៖ គឺជាលោហធាតុពណ៌សទឹកប្រាក់ភ្លឺរលោងតាមធម្មតាកើតមាននៅក្នុងរ៉ែដែកនីកែលប្រាក់ និងទង់ដែក។ ភាគច្រើនត្រូវប្រើនៅក្នុងលោហធាតុផ្សំម៉ាញេទិកសីតុណ្ហភាពខ្ពស់ និងធន់នឹងទឹកសម្រាប់វត្ថុដូចជាតួប៊ីនឧស្ម័នផ្នែកជួសជុល និងការស្រោប ឬប៉ានអេឡិចត្រូនិក។ អំបិលកូបាល់ត៍ត្រូវគេប្រើសម្រាប់អាគុយទន់។ កូប័លក៏ត្រូវគេប្រើជាជាតិពណ៌សម្រាប់កាចាព័រសីឡែន និងលាបពណ៌កែវផងដែរ។

**ឧស្ម័នធម្មជាតិបង្ហាប់** (Compressed Natural Gas CNG)៖ គឺជាឧស្ម័នធម្មជាតិដែលបានបង្ហាប់ឲ្យណែនក្រោមសម្ពាធខ្ពស់ ជាតួយ៉ាងចន្លោះពី២០០០ និង ៣៦០០psi, ទុកនៅក្នុងកុងតឺន័រ។ឧស្ម័ននេះរីកមាឌនៅពេលបញ្ចេញជាឥន្ធនៈ។

**ផលិតផល** (Commodity): គឺជាវត្ថុធាតុដើម(លោហធាតុ) ឬផលិផលបឋម (អាហារ ធុញ្ញជាតិ។ល។) ដែលអាចទិញ និងលក់តាមធម្មតាតាមរយៈកិច្ចសន្យា ឬកិច្ចព្រមព្រៀង □នាពេលអនាគត□ ដើម្បីទិញឬលក់វត្ថុធាតុទាំងនោះតាមតម្លៃជាកំណត់ប៉ុន្តែត្រូវដឹកជញ្ជូន និងបង់ប្រាក់នៅពេលក្រោយ។

**សម្បទាន** (Concession)៖ នៅក្នុងបរិបទឧស្សាហកម្មនិស្សារណកម្មសម្បទានគឺជាផ្តល់លទ្ធភាពសម្រាប់តំបន់ប្រើប្រាស់ជាកំណត់ណាមួយ និងក្នុងរយៈពេលដែលត្រូវផ្ទេរសិទ្ធិមួយចំនួនក្នុងការប្រើប្រាស់ឧទង្គារដែលអាចស្រាវជ្រាវឃើញពីប្រទេសម្ចាស់ផ្ទះ ដើម្បីធ្វើអាជីវកម្ម។

**កម្ចីសម្បទាន** (Concessional Loan)៖ កម្ចីដែលផ្តល់ទៅឲ្យប្រទេសក្រីក្របំផុតដែលមានអត្រាការប្រាក់ទាប និងរយៈពេលសងវែងជាងកម្ចីទីផ្សារធម្មតា ឬស្តង់ដារ ឬកម្ចីពហុភាគីឧទាហរណ៍ទាបជាងអត្រាការប្រាក់ និងមានរយៈពេលអនុគ្រោះវែង។ អាចហៅម៉្យាងទៀតថា □កម្ចីដែលមានការប្រាក់ទាប (soft loan)□។

**សម្ភារៈសំណង់សង់** (Construction materials)៖ សម្ភារៈដែលមានលក្ខណៈសមស្របសម្រាប់ការសាងសង់ដែលភាគច្រើនជាថ្ម ឬសម្ភារៈលើដីដូចជា ថ្មក្រានីត បាសាល ថ្មភក់ ថ្មបាយក្រៀមខ្សាច់ដីឥដ្ឋ និងដីក្រហមជាដើម។

**អ្នកម៉ៅការ** (Contractor)៖ នៅក្នុងបរិបទឧស្សាហកម្មនិស្សារណកម្មអ្នកម៉ៅការគឺជាក្រុមហ៊ុនឯករាជ្យដែលផ្តល់សេវាដល់ម្ចាស់ឧស្សាហកម្មនិស្សារណកម្ម (ក្រុមហ៊ុនធ្វើរ៉ែប្រេង និងឧស្ម័នជាដើម) តាមអាណត្តិកាលដែលមានចែងជាក់លាក់នៅក្នុងកិច្ចសន្យាម៉ៅការ។ តាមធម្មតាភាពជាដៃគូត្រូវកំណត់ដោយឆន្ទៈរបស់អ្នកម៉ៅការដើម្បីរុករក និងធ្វើអាជីវកម្មលើតំបន់ម៉ៅការមួយដោយប្រឈមមុខនឹងហានិភ័យផ្នែកហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់ក្នុងអាជីវកម្មដែលគ្រប់គ្រងដោយកិច្ចសន្យាចែករំលែកផលិតកម្ម (production-sharing contract PSC)។

**ការធ្វើរ៉ែដោយបន្ត** (Continuous Mining)៖ គឺជាវិធីសាស្ត្រធ្វើរ៉ែដោយប្រើប្រាស់គ្រឿងម៉ាស៊ីនដែលធ្វើកិច្ចការនិស្សារណកម្មទាំងមូល ដោយលុបបំបាត់នូវវដ្តជាប្រពៃណីទាំងបួនរួមមានការកាត់ខួងបំផ្ទុះ និងផ្ទុក។ សម្ភារៈដែលត្រូវបានធ្វើនិស្សារណកម្មតំបន់ទំនាបបន្សល់ទុកនូវ □សសរស្តម្ភ(pillars)□ នៃវត្ថុធាតុមិនទាន់ប៉ះពាល់ដើម្បីទ្រទ្រង់□ដំបូល□និងទុកតំបន់ឲ្យនៅចំហឬ□ចន្លោះ□នៅក្រោមដី។ ភាគច្រើនបំផុតត្រូវប្រើប្រាស់សម្រាប់ស្រទាប់រ៉ែវាលរាប ជាពិសេសស្រទាប់ថ្មឬ □ជាន់ថ្នាក់នៃរ៉ែ/stratum.□ ។ គេអាចហៅម្យ៉ាងទៀតថាការធ្វើរ៉ែ □ក្តារបន្ទះនិងសសរស្តម្ភ/bord និង pillar□ ។

**ការធ្វើរ៉ែតាមបែបបុរាណ** (Conventional Mining)៖ គឺជាវិធីសាស្ត្រធ្វើរ៉ែក្រោមដីដោយគ្រឿងចក្រទាំងស្រុងទីមួយដោយការបញ្ចូលគ្រឿងផ្ទុះ នៅក្នុងរង្វះធ្យូងថ្មការបំផ្ទុះរង្វះធ្យូងថ្ម និងការរើធ្យូងថ្មចូលទៅក្នុងយានដឹកឬរថយន្ត shuttle car ដោយម៉ាស៊ីនផ្ទុក។

**ទង់ដែង** (Copper)៖ គឺជាលោហធាតុទន់ដែលមានលទ្ធភាពចម្លងកម្ដៅ និងអគ្គិសនីខ្ពស់ប្រើសម្រាប់ឧបករណ៍ចម្លងកម្ដៅ និងអេឡិចត្រូនិក និងជាសម្ភារៈសាងសង់។ វាគឺជាសមាសធាតុនៃសំលោហៈដែកផ្សេងៗដែលជាធាតុផ្សំនៅក្នុងថ្នាំលាបសេរ៉ាមិក ហើយជាសម្ភារៈដ៏សាមញ្ញសម្រាប់ធ្វើកាក់ប្រាក់ផងដែរ។

**ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន** (Corporate Social Responsibility/CSR)៖ គឺជាការប្តេជ្ញាចិត្តជាបន្តដោយអាជីវកម្មក្នុងការប្រព្រឹត្តប្រកបដោយសីលធម៌ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចដោយជាមួយគ្នានោះកែលម្អគុណភាពជីវិតរបស់កម្លាំងពលកម្ម និងក្រុមគ្រួសាររបស់ពួកគេព្រមទាំងសហគមន៍មូលដ្ឋាន និងសង្គមជាតិទាំងមូល។

**ប្រេងឆៅ** (Crude Oil)៖ គឺជាប្រេងឥន្ធនៈមិនទាន់ចម្រាញ់ជាវត្ថុរាវកើតឡើងតាមធម្មជាតិអាចឆាបឆេះ មានសមាសភាគទៅដោយល្បាយស្មុគ្រស្មាញនៃអ៊ីត្រូកាបូនទម្ងន់ម៉ូលេគុលផ្សេងៗព្រមទាំង សមាសភាគសរីរាង្គដទៃទៀតឃើញមាននៅក្នុងកំណកំណើតផែនដីនៅក្រោមផ្ទៃផែនដី។

**ការច្រោះថ្នាំជ្រលក់ពណ៌ឬការច្រោះដោយពំនូកថ្នាំជ្រលក់ពណ៌** (Cyanide

leaching or cyanide heap leaching): គឺជាដំណើរការធ្វើរ៉ែជាលក្ខណៈឧស្សាហកម្ម ដើម្បីធ្វើនិស្សារណកម្មលោហធាតុមានតម្លៃដូចជាមាសពីរ៉ែមាសជាដើម។ រ៉ែដែកដែលត្រូវបំបែកធាតុត្រូវគេរជាភ្នកនៅលើទ្រនាប់ ឬទីតាំងរួចហើយត្រូវបាញ់ស្រោចដោយល្បាយថ្នាំជ្រលក់។ ធាតុថ្នាំជ្រលក់បាញ់ទៅលើមាសខណៈពេលឆ្លងកាត់ពំនូករ៉ែ។ វត្ថុធាតុនៅសល់ក្រោមពំនូកត្រូវបូមបញ្ចូលទៅក្នុងម៉ាស៊ីនមួយដើម្បីធ្វើការបំបែកធាតុបែបគីមី។ ថ្នាំជ្រលក់ដែលនៅសល់ត្រូវផ្ទុកនៅក្នុងត្រពាំងសិប្បនិម្មិត។ ការធ្វើឲ្យខូចបរិស្ថានជុំវិញជាពិសេសផ្ទៃដីនិងទឹកដោយសារការលិចធ្លាយថ្នាំជ្រលក់ពិតជាមិនអាចចៀសវាងបានឡើយ។ (សូមមើលពាក្យ ) □ការច្រោះដោយពំនូកថ្នាំជ្រលក់ផងដែរ /heap leaching.□)

# D

**ការរើចេញ** (Decommissioning)៖ គឺជាការបិទ និងសំអាតរ៉ែបន្ទាប់ពីបញ្ចប់ការយករ៉ែ។ ការងារនេះរួមមានការរុះរើអគារ និងសម្ភារៈចេញ ។ ការអនុវត្តន៍ដ៏ល្អគឺមានការយកចេញ និងបោះចោលនូវវត្ថុដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដើម្បីសុវត្ថិភាព ការរៀបចំបរិវេណទីតាំងឲ្យបានដូចមុនពេលយករ៉ែ និងការតាមដានផលប៉ះពាល់បរិស្ថានរយៈពេលវែង ។

**អណ្តូងរ៉ែជ្រៅ** (Deep Mine)៖ មានជម្រៅលើសពី ៩០០ ម៉ែត្រក្រោមដី។

**ស្រទាប់រ៉ែ** (Deposit)៖ ជាបណ្តុំរ៉ែ ឬប្រេង ឬឧស្ម័ន ដែលមានបរិមាណ និងគុណភាពសមរម្យអាចធ្វើអាជីវកម្មផ្នែកសេដ្ឋកិច្ចបាន។

**ដង់ស៊ីតេ** (Density)៖ ម៉ាស ឬទំងន់នៃសារធាតុក្នុងមួយម៉ែត្រគូប។

**ការរុករករ៉ែក្នុងបាតសមុទ្រជ្រៅ** (Deep Water Exploration)៖ ការស្វែងរកប្រេងឧស្ម័ន ឬរ៉ែផ្សេងទៀតដែលរ៉ែទាំងអស់ ឬផ្នែកខ្លះនៃរ៉ែស្ថិតនៅជម្រៅទឹកលើសពី ២០០ ម៉ែត្រ។

**ដឺរិក** (Derrick) ៖ ជាសំណង់សម្រាប់លើកដាក់ និងទ្រទ្រង់ឧបករណ៍ខួងពីលើមាត់អណ្តូងប្រេង/ឧស្ម័ន។ ដឺរិកមានសណ្ឋានដូចជា ប៉មដែលមានជើងទម្របួននៅតាមជ្រុងនីមួយៗ ពីក្រោមដល់លើ។ នៅលើផ្ទៃទឹក ដឺរិកធំៗខ្លះត្រូវបានគេដាក់

ពីលើនាវាដែលមានឈ្មោះថា ដីរិកបណ្តែត ឬឧបករណ៍ខួងយកប្រេង ឬឧបករណ៍ខួងយកប្រេង (oil rig)។

**ការជីកអណ្តូងរ៉ែ** (Development Mining)៖ គឺជាការជីកយកថ្ម ឬដីដែលគ្មានតម្លៃចេញដើម្បីយករ៉ែ។ ការជីកនេះ រួមទាំងការដាំពន្លិចសសរដែក ការកាត់ ខួង និងលើកដាក់ជាដើម។ ការជីកនេះគឺសំខាន់ណាស់ចំពោះ (ផលិតកម្មរ៉ែ)។

**ភាគលាភ** (Dividend)៖ គឺជាការបង់ប្រាក់ទៅឲ្យដៃគូ ឬម្ចាស់ភាគហ៊ុននូវផលចំណេញដែលក្រុមហ៊ុនទទួលបានពីការបណ្តាក់ទុន។

**ផ្នែកខាងក្រោម** [Downstream Sector] ៖ គឺជាផ្នែកមួយក្នុងចំណោមផ្នែកបីក្នុងប្រតិបត្តិការយកប្រេង និងឧស្ម័ន (ផ្នែកពីទៀតមានផ្នែកលើ [upstream] និងផ្នែកកណ្តាល [mid-stream])។ ការធ្វើអាជីវកម្មប្រេងផ្នែកក្រោមនេះសំដៅលើការលក់ ឬចែកចាយឧស្ម័នធម្មជាតិ និងផលិតផលចេញពីប្រេងឆៅ តែក៏អាចដាក់បញ្ចូលសកម្មភាពរបស់ផ្នែកកណ្តាលបានដែរដូចជាការចម្រាញ់និងដឹកជញ្ជូន។

**ការបូម** (Dredging)៖ ជាដំណើរការបូមយកវត្ថុនៅក្នុងទឹក។ ដូចជាការបូមយកខ្សាច់ ក៏ដូចជាល្បាប ដែលជារ៉ែ រួមមានសំណ មាស និងពេជ្រជាដើម។ ការបូមក៏គេធ្វើដើម្បីឲ្យកំពង់ផែ និងទន្លេមានជម្រៅជ្រៅជាដើម ។

**ម៉ាស៊ីនបូម** (Dredge)៖ គឺជាឧបករណ៍ដែលតាំងលើសាឡង់ (អណ្តែត) ដែលមានបំពង់តដល់បាតក្រោមទឹកដើម្បីជីក បូមដីមកលើផ្ទៃទឹកដាក់លើសាឡង់។

**ខួង/ឧបករណ៍ខួង** (Drill)៖ (កិរិយាស័ព្ទ) ដើម្បីធ្វើជារូងក្នុងដី ឬថ្មដោយប្រើចលនាអ្វីក៏បាន។ (នាម) ជាឧបករណ៍សម្រាប់ខួង។

**លិខិតអនុញ្ញាតឲ្យខួង** (Drilling Permit)៖ ជាការផ្តល់សិទ្ធិឲ្យមានការខួងនៅទីតាំងណាមួយដែលជាការតម្រូវរបស់ប្រទេស ឬរដ្ឋមួយ។

**ម៉ាស៊ីនខួង** (Drilling rig)៖ ជាម៉ាស៊ីនសម្រាប់ធ្វើជារូង ឬរន្ធ និងមានបញ្ចេញអាចម៍ដី។ ម៉ាស៊ីនខួងនេះអាចធ្វើលើដី ឬលើទឹកដែលហៅថាសំណង់បូម/ខួងប្រេងក្នុងសមុទ្រ ។

# E

**ការវាយតម្លៃផ្នែកសេដ្ឋកិច្ច** (Economic Evaluation)៖ គឺជាការបូកសរុបនូវគម្រោងរបស់ក្រុមហ៊ុនដើម្បីកំណត់នូវលទ្ធភាពចំណេញ ឬមើលថាគម្រោងត្រូវចំណាយច្រើនពេកមិនអាចចំណេញបាន ។

**ការបង្កើតនូវប្រព័ន្ធអេកូឡូស៊ីឡើងវិញ** (Ecosystem Restoration)៖ គឺជាការស្តារទីតាំងយករ៉ែឡើងវិញដើម្បីឲ្យមានប្រព័ន្ធអេកូឡូស៊ីដំណើរការដូចដើម ។

**ល្បាយរ៉ែ** (Effluent)៖ ជាល្បាយដែលមានប្រេង ឧស្ម័ន ទឹក និងខ្សាច់ពេលយកពីអណ្តូងរ៉ែ ។

**គំនិតផ្តួចផ្តើមស្តីពីតម្លាភាពរបស់ឧស្សាហកម្មរ៉ែ** (Extractive Industries Transparency Initiative) (EITI)៖ ជាកិច្ចផ្តួចផ្តើមសកលដែលគាំទ្រឲ្យមានអភិបាលកិច្ចប្រសើរឡើងក្នុងប្រទេសដែលសម្បូណ៌ធនធានតាមរយៈការបញ្ជាក់ និងបោះពុម្ពទាំងស្រុងនូវការបង់ប្រាក់ពីក្រុមទៅក្នុងថវិកាជាតិ រដ្ឋាភិបាលពីការយកប្រេង ឧស្ម័ន និងរ៉ែ។ EITI គឺជាការរួមគ្នារវាងរដ្ឋាភិបាល ក្រុមហ៊ុន អង្គការសង្គមស៊ីវិល វិនិយោគិន និងអង្គការអន្តរជាតិនានា ។

**EITI Plus Plus,** (EITI ++): ជាអំណះអំណាងទៅនឹងការអនុវត្តប្រភេទណាមួយនៃ EITI ដែលអាចត្រូវបានគេរៀបចំឡើងដោយប្រទេសមួយដែលហួសពីស្តង់ដារស្នូល និងតម្រូវការរបស់ EITI ដែលមានចែងក្នុងឯកសាររបស់ EITI ឯកសារណែនាំពីសុពលភាព EITI និងប្រភពផ្សេងៗទៀត។ នេះគឺជាការពង្រីកបន្ថែមនៃដំណើរការ EITI ដែលផ្តល់នូវជម្រើសដើម្បីបង្កើនថវិការជាតិប្រកបដោយប្រសិទ្ធភាពសម្រប់អភិវឌ្ឍជាតិ ។

**សៀវភៅ EITI EITI** (Sourcebook)៖ សៀវភៅ EITI ផ្តល់នូវសេចក្តីណែនាំអំពីរបៀបដែលពាក់ព័ន្ធនឹង EITI។ សៀវភៅនេះផលិតដោយលេខាធិការដ្ឋាន EITI អន្តរជាតិ។ វាមានគោលបំណងជួយដល់ប្រទេសនានាដែលចង់អនុវត្ត EITI និងអ្នកពាក់ព័ន្ធដែលចង់គាំទ្រដល់ការអនុវត្តនេះ។

**ការប៉ាន់ប្រមាណផលប៉ះពាល់ដល់បរិស្ថាន** Environmental Impact Assessment (EIA) ៖ គឺជាការវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់វិជ្ជមាន ឫអវិជ្ជមានដែលអាចមានចំពោះធម្មជាតិ សង្គម និងសេដ្ឋកិច្ច ដែលគម្រោងរដ្ឋ ឫឯកជនអាចមានលើបរិស្ថាន។ គោលបំណងនៃការប៉ាន់ប្រមាណនេះ គឺដើម្បីធានាថា អ្នកសម្រេចចិត្ត មុននឹងសម្រេចចិត្តឲ្យអនុវត្តគម្រោង និងរៀបចំគម្រោង គឺបានពិចារណាត្រឹមត្រូវអំពីផលប៉ះពាល់នេះ។

**ផែនការគ្រប់គ្រងបរិស្ថាន** Environmental Management Plan (EMP)៖ គឺជាផែនការរបស់ក្រុមហ៊ុនស្តីអំពីរបៀបដែលក្រុមហ៊ុនត្រូវធ្វើដើម្បីការពារបរិស្ថានក្នុងអំឡុងពេលគ្រប់ដំណាក់កាលនៃការយករ៉ែរួមមានការសាងសង់ ការជីកយករ៉ែ ការចម្រាញ់ ការបិទទីតាំង និងការស្តារទីតាំងនោះឡើងវិញ ។

**ការរុករក** (Exploration)៖ ជាវិធីសាស្រ្តណាក៏ដោយដែលបានប្រើដើម្បីស្វែងរកទីតាំងប្រេងនិងឧស្ម័នថ្មី ។

**ថ្លៃដើមរុករក** (Exploration Costs)៖ គឺជាចំនួនប្រាក់ដែលបានចំណាយលើការងាររុករក ។

**អាជ្ញាប័ណ្ណរុករក** (Exploration License)៖ គឺជាលិខិតប័ណសម្គាល់ថា មានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលឲ្យក្រុមហ៊ុនមួយរុករកប្រេង និងឧស្ម័ន ។

**ឧស្សាហកម្មយករ៉ែ** (Extractive Industries)៖ ឧស្សាហកម្មនេះរួមមាន ប្រេង ឧស្ម័ន និងរ៉ែ និងលោហៈ។ វាក៏រាប់បញ្ចូលនូវការយកសម្ភារៈសំណង់លើដីដូចជា ខ្សាច់ និងថ្ម។

**EISEI**៖ មកពីពាក្យថា The Extractive Industry Social and Environmental Impact (EISEI) Network បណ្តាញស្តីពីផលប៉ះពាល់លើសង្គមបរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម។ វាជាបណ្តាញមួយដែលបង្កើតឡើងដើម្បីបម្រើដល់បណ្តាញជាតិ ហើយការងារ EISEI គឺផ្តោតទៅលើទំនាក់ទំនងគ្នា ការចែករំលែកព័ត៌មាន និងសម្របសម្រួលការសន្ទនាគ្នារវាងសហគមន៍ អង្គការនៅសហគមន៍ ក្រសួងរបស់រដ្ឋាភិបាល និងក្រុមហ៊ុនអាជីវកម្មរ៉ែ អំពីឧស្សាហកម្ម

និស្សារណកម្ម ដោយមានការគាំទ្រ និងសម្របសម្រួលពីអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព។ EISEI មានសមាជិកគណៈកម្មាធិការដឹកនាំចំនួន ៩រូប ដែលបោះឆ្នោតដោយបណ្តាញជាសមាជិក ។

# F

**កត្តាសុវត្ថិភាព** (Factor of Safety)៖ គឺជាសម្ភារៈការងារដែលមានសមត្ថភាពអាចធន់នឹងទំងន់ ឫការដាច់។ ប្រសិនបើខ្សែពួរមួយនឹងដាច់នៅទំងន់ ៦០០០ផោន (២៧២១គក្រ) ហើយគេប្រើខ្សែ នោះដើម្បីយោងវត្ថុទំងន់តែ ២០០០ផោន (៩០៦ គក្រ) នោះយើងឃើញកត្តាសុវត្ថិភាពគឺ ៦០០០ ចែកនឹង ២០០០ ដែលស្មើនឹង៣។

**ស្នាមផ្ទាំងទ្វីប** (Fault) ៖ គឺជាស្នាមដែលប៉ះគ្នារវាងផ្ទាំងទ្វីបពីរ។ ភស្តុតាងបង្ហាញពីស្នាមនេះមានដូចជាភ្នំឫកោះ ហើយគ្រោះថ្នាក់រញ្ជួយផែនដីតែងតែកើតឡើងនៅលើ □ខ្សែស្នាម□នេះ។

**ការសិក្សាពីលទ្ធភាព** (Feasibility Study) ៖ ជាការសិក្សាវាយតម្លៃលើលទ្ធភាពផ្នែកហិរញ្ញវត្ថុ ហានិភ័យផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងភាពមាំមួននៃគម្រោង។ ក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ការសិក្សាពីលទ្ធភាពជួយឲ្យវិនិយោគិនប្រមូលទុនដើម្បីធ្វើប្រាក់បម្រុងដែលហើយអាចបំលែងទៅជាផលចំណេញ។

**វិធីបំបែកថ្មដោយសម្ពាធ** (Fracking)៖ ជាដំណើរការបំបែកផ្ទាំងថ្មដោយការខួងថ្មរួចចាក់អង្គធាតុរាវចូល (ជារឿយៗ អង្គធាតុរាវទាំងនោះជាជាតិគីមីមានគ្រោះថ្នាក់) ហើយធ្វើឲ្យមានសម្ពាធខ្លាំងដើម្បីបំបែកថ្មក្នុងគោលបំណងអាចទទួលបានទិន្នផលរ៉ែប្រេង និងឧស្ម័នខ្ពស់។ វាជាការអនុវត្តដែលមានភាពចំរូងចំរាស់។ ការបារម្ភពីផលប៉ះពាល់លើបរិស្ថាន និងសុខភាពពីការប្រើវិធីនេះមានដូចជា វាអាចបំពុលទាំងទឹកក្រោមដី និងលើដី បង្កឲ្យមានការបំពុលបរិយាកាសមានការភាយឧស្ម័ន និងសារធាតុគីមីនៅលើដី មិនមានការចោលកាកសំណល់បានល្អ និងប៉ះពាល់ដល់ស្រទាប់ថ្មដែលអាចបង្កឲ្យមានរញ្ជួយផែនដី។ វិធីនេះក៏ហៅ វិធីបំបែកដោយទឹក ។

**ប្រេងផូស៊ីល** (Fossil fuels)៖ គឺជាប្រភេទរ៉ែអ៊ីដ្រូកាបូន ដូចជា ប្រេងកាត ឧស្ម័ន

និងត្បូងថ្ម ដែលគេយកពីក្រោមដីដើម្បីប្រើប្រាស់ផលិតជាថាមពល ។

# G

**ដីស្រោបរ៉ែ** (Gangue)៖ ជាប្រភេទដីដែលគ្មានតម្លៃ តែមានលាយឡំជាមួយរ៉ែដែក ។

**ឧស្ម័ន** (Gas)៖ ជាអង្គធាតុរាវដែលអាចឆេះ ឬមិនឆេះ ហើយដែលកើតពីធម្មជាតិក្នុងដី។ វាមានសណ្ឋានជាឧស្ម័នដែលអាចក្លាយអង្គធាតុរាវនៅសីតុណ្ហភាពធម្មតា ឬរងសម្ពាធ។

**គំរបឧស្ម័ន** (Gas Cap)៖ គឺជាស្រទាប់ឧស្ម័ននៅផ្នែកខាងលើនៃអាងស្តុកដែលនៅទីនោះលក្ខខណ្ឌសម្ពាធ និងអង្គធាតុរាវអំណោយផលឲ្យមានជាឧស្ម័ន។ ការរកឃើញគំរបឧស្ម័ននេះគឺជាការផ្តល់សញ្ញាថាអាចមានកំណប់ប្រេងកាត ។

**រោងចក្រឧស្ម័ន ឬរោងចក្រចម្រាញ់ឧស្ម័ន** (Gas Plant or Gas Processing Plant) ៖ ជាទីតាំង (រោងចក្រ) ដែលចម្រាញ់ឧស្ម័នពីក្នុងដីតាមរយៈអណ្តូងរ៉ែ។ នៅរោងចក្រ គេបំបែកធាតុទឹកឲ្យចេញពីឧស្ម័ន ហើយឧស្ម័នត្រូវបានសង្កត់ដោយសម្ពាធឲ្យក្លាយជាអង្គធាតុរាវដើម្បីទុកដាក់ ដឹកជញ្ជូន ឬបង្ហូរតាមបំពង់ ។

**ការបំលែងទៅជាឧស្ម័ន** (Gasification)៖ ជាដំណើរការនានាដែលបំលែងត្បូងថ្មឲ្យទៅជាឧស្ម័នដែលមាន BTU ទាប មធ្យម និងខ្លាំង។

**ឧបករណ៍ស្ទង់វិទ្យុសកម្ម** (Geiger Counter) ៖ ជាឧបករណ៍ប្រើសម្រាប់ស្វែងរករ៉ែណាដែលមានបំភាយជាតិវិទ្យុសកម្មជាពិសេស អ៊ុយ៉ារ៉ានីញ៉ូម ព្រោះដោយប្រើបំពង់ទីបរបស់ខ្លួនឧបករណ៍នេះមានសមត្ថភាពស្ទង់កាំរស្មីដែលភាយចេញពីរ៉ែទាំងនោះ។ ឧបករណ៍នេះបង្ហាញពីវត្តមាន និងកម្រិតវិទ្យុសកម្មដោយបញ្ចេញពន្លឺ ឬបន្លឺសំលេង ឬបញ្ចេញទាំងពន្លឺ និងបន្លឺសំលេង។

**ត្បូងថ្ម ឬត្បូង** (Gemstone or Gem)៖ ជាធម្មតាវាក៏ជារ៉ែដែរដែលនៅពេលកាត់ និងច្នៃវាក្លាយទៅជាឧបករណ៍សំអាងដ៏មានតម្លៃ។ តម្លៃត្បូងអាស្រ័យទៅតាម ទឹក ពណ៌ លក្ខណៈផ្សេងៗ និងភាពកម្រ។ ឧទាហរណ៍ ត្បូងទទឹម ត្បូង

មរកត និងត្បូងកណ្ដៀង ។ ទោះជាសារធាតុសរីរាង្គរឹងមួយចំនួនដូចជា គុជ ថ្មកែវពណ៌លឿងថ្លា (កកើតពីកំណកជ័រឈើដែលមានអាយុកាលយូរ) និងថ្មពណ៌ខៀវចាស់ មិនមែនជារ៉ែក៏ដោយ ក៏ថ្មទាំងអស់នេះនៅតែគេសន្មត់ថាជាត្បូងដែរ ។ (នៅពេលខ្លះគេហៅថ្មទាំងនេះថាជា ថ្មមានតម្លៃ ឬថ្មមានតម្លៃមធ្យម)។

**ផែនទីភូគព្ភ** (Geological Maps)៖ ជាផែនទីដែលបង្ហាញពីទីតាំងដីក្នុងតំបន់មួយរួមទាំងថ្ម ដី និងខ្សាច់ខុសៗគ្នាដែលមានវត្តមាននៅទីនោះ។

**ភូគព្ភសាស្ត្រ** (Geology)៖ ជាវិទ្យាសាស្ត្រដែលសិក្សាពីដើមកំណើត និងរចនាសម្ព័ន្ធនៃផែនដី រួមទាំងបណ្ដុំថ្ម និងការផ្លាស់ប្ដូរទ្រង់ទ្រាយ គីមី និងជីវសាស្ត្រដែលបាន និងកំពុងតែមានឥទ្ធិពលលើវា។

**ថាមពលកម្ដៅផែនដី** (Geothermal Power)៖ ជាថមពលដែលបានមកពីកម្ដៅផែនដី។ ថាមពលកម្ដៅផែនដីនេះ កកើតមកពីកំណកំណើតនៃផែនដី គឺពីការបំភាយវិទ្យុសកម្មចេញពីរ៉ែ និងថាមពលព្រះអាទិត្យដែលស្រូបពីផ្ទៃក្រៅនៃផែនដី។

**ការឡើងកម្ដៅផែនដី** (Global Warming)៖ គឺជាការកើនឡើងនៃកម្ដៅផែនដីដោយសារតែការបំភាយឧស្ម័នផ្ទះកញ្ចក់ ជាពិសេសឧស្ម័នកាបូនិច។ ការឡើងកម្ដៅផែនដីនេះក៏គេស្គាល់ថាជា □បម្រែបម្រួលអាកាសធាតុ□ ដែរ ។

**មាស** (Gold)៖ ជាលោហៈមានតម្លៃពណ៌លឿង(ពណ៌មាស) ទន់ងាយបត់បែន ហើយមិនមានអុកស៊ីតកម្ម ឬប្រតិកម្មគីមីដូចជាដុះច្រេះ ឬស្នឹម។ ប្រមាណ ៨០ ទៅ ៩០ ភាគរយនៃរ៉ែមាសទើបតែជីកត្រូវបានគេប្រើធ្វើជាគ្រឿងអលង្ការ និងសំអាង។ ភាគរយដែលនៅសល់ត្រូវបានគេយកទៅប្រើយកទៅស្រោបលើលោហៈដទៃទៀត និងដុំចម្លងអគ្គីសនី និងឱសថព្យាបាលជំងឺសន្លាក់ និងសាច់ដុំ។

**ទំនាញដី**(Gravity)៖នៅក្នុងភូគព្ភសាស្ត្រ□ទំនាញដី□ពិពណ៌នាអំពីដង់ស៊ីតេរបស់រ៉ែ នៅពេលប្រៀបធៀបរវាងទំងន់ និងមាឌរបស់វា ។ គ្រប់រ៉ែទាំងអស់មានទំនាញដី (ទម្ងន់) ពិសេសខុសៗគ្នាដែលកំណត់លក្ខណៈរបស់ខ្លួន។

**ថាមពលបៃតង** (Green Energy)៖ ជាថាមពលចេញពីប្រភពធម្មជាតិអាចក

កើតដោយឯកឯងឡើងវិញ ដោយមានប្រសិទ្ធភាពខ្ពស់ មានផលប៉ះពាល់តិចតួច ឬគ្មានប៉ះពាល់ដល់បរិស្ថានឡើយ ហើយនិងមានកម្រិតស្ថិរភាពយូរអង្វែង។ ថាមពលនេះរួមមាន ថាមពលពីការពុកផុយរលួយនៃសំរាម ថាមពលកម្តៅផែនដី កំលាំងខ្យល់ វារីអគ្គីសនីធុនតូច ថាមពលព្រះអាទិត្យ ថាមពលរលកទឹក ថាមពលពីចលនាទឹកជោលាជនៃសមុទ្រ។ ថាមពលជីវសាស្រ្តមួយចំនួន ក៏អាចធ្វើបានទៅតាមវិធីសាស្រ្តក្នុងការផលិត (រុក្ខជាតិ ឬលាមក) ។ (សូមមើល ថាមពលប្រកបដោយនិរន្តរភាព និង ថាមពលកកើតឡើងវិញ)

**ផលប៉ះពាល់ផ្ទះកញ្ចក់** (Greenhouse Effect)៖ ជាកម្តៅផែនដី និងកម្តៅបរិយាកាសបានមកពីការទាញកម្តៅរបស់ព្រះអាទិត្យដោយ ឧស្ម័នកាបូនិច ចំហាយទឹក មេតាន អុកស៊ីតនីត្រាត កាបូនក្លរ៉ូផ្លុយអ័រ និងឧស្ម័នផ្សេងៗទៀតទាំងក្នុងធម្មជាតិ ទាំងឧស្ម័នបង្កើតដោយមនុស្ស ។

# H

**ការច្រោះពំនូករ៉ែ** (Heap leaching)៖ គឺជាដំណើរការធ្វើរ៉ែជាលក្ខណៈឧស្សាហកម្ម ដើម្បីធ្វើនិស្សារណកម្មលោហធាតុមានតម្លៃ ទង់ដែង អ៊ុយ៉ារ៉ានីយញ៉ូម និង សមាសធាតុដទៃទៀតពីរ៉ែ។ រ៉ែដែលត្រូវបានបំបែកធាតុ ត្រូវគរជាភ្នកលើទ្រនាប់ ឬបាតផ្ទៃ រួចហើយបាញ់លាយជាមួយល្បាយពណ៌រាវ (ក្នុងករណីមាស ឬ លោហធាតុមានតម្លៃ) ឬល្បាយអាស៊ីដស៊ុយហ្វួរិក សម្រាប់ទង់ដែង នីកែល និង រ៉ែអ៊ុយ៉ារ៉ាញ៉ូម។

**ការខួងរ៉ែតាមបន្ទាត់ផ្ដេក**(HorizontalDrilling)៖គឺជាដំណើរការនៃការខួងអណ្ដូងរ៉ែពីផ្ទៃដីទៅកាន់ទីតាំងក្រោមផ្ទៃដី នៃអាងរ៉ែ ឬឧស្ម័នជាគោលដៅ រួចហើយខួងតាមចំហៀងទៅកាន់អាងរ៉ែនោះ ដើម្បីយករ៉ែឬឧស្ម័នចេញ។ ដោយសារអាងរ៉ែភាគច្រើនបំផុតមានបណ្ដោយវែងជាទទឹងនោះ គេអាចធ្វើនិស្សារណកម្មរ៉ែ/ឧស្ម័នបានកាន់តែច្រើន។ ជារឿយៗ ការខួងផ្ដេកត្រូវអមដោយរបៀបធ្វើរ៉ែមានលក្ខណៈវាទប្បដិវាទមួយបែប ហៅថាការបំបែករ៉ែដោយបញ្ចូលធាតុគីមី (fracking)។ (សូមមើលពាក្យថាការបំបែករ៉ែដោយធាតុគីមី (fracking)។

**អ៊ីត្រូកាបូន** (Hydrocarbon) ៖ សមាសធាតុគីមីមួយក្រុម ដែលមានអាតូមកាបូន

និងអ៊ីត្រូហ្សែននៅក្នុងល្បាយផ្សេងៗ ឃើញមានជាពិសេសនៅក្នុងផូស៊ីលឥន្ធនៈ។

**ជលវិទ្យា** (Hydrology)៖ ការសិក្សាអំពីចលនា របាយ និងគុណភាពទឹកនៅទូទាំងភពផែនដី។

## I

**សិលាកំអែភ្នំភ្លើង** (Igneous Rock)៖ គឺជាប្រភេទសិលាមួយក្នុងចំណោមប្រភេទសិលាសំខាន់ៗបី (ប្រភេទដទៃទៀត គឺសិលាល្បប់ និងសិលាប្រែក្លាយរូបរាង)។ សិលាកំអែភ្នំភ្លើង ត្រូវបង្កើតឡើងដោយម៉ាកម៉ា (សិលារលាយ ឬសិលាពរដូចជាចេញពីភ្នំភ្លើង ជាដើម) ដែលបានត្រជាក់ រួចហើយក្លាយជារឹង។

**ការជីករករ៉ែខុសច្បាប់** (Illegal Mining): សកម្មភាពធ្វើរ៉ែដែលគ្មានអាជ្ញាប័ណ្ណ ឬមិនបានចុះបញ្ជី ឬមិនបានធ្វើប្រតិបត្តិការតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ ក្នុងករណីធនធានរ៉ែក្រោមដី ដែលជាកម្មសិទ្ធិរបស់រដ្ឋ និងត្រូវបានគ្រប់គ្រងដោយរដ្ឋ។ ការធ្វើរ៉ែខុសច្បាប់ ត្រូវកត់សម្គាល់ដោយការគ្មានសិទ្ធិដីធ្លី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតរុករក ឬជីកជញ្ជូនរ៉ែ និងមានលក្ខណៈតូចតាច។ នេះមិនមែនមានន័យថា ការធ្វើរ៉ែជាលក្ខណៈសិប្បកម្ម គឺជាការខុសច្បាប់ទេ។ នៅក្នុងរដ្ឋមួយចំនួន ការធ្វើរ៉ែជាលក្ខណៈសិប្បកម្ម កើតមានឡើងដំណាលគ្នាជាមួយការធ្វើរ៉ែជាលក្ខណៈឧស្សាហកម្មដែរ។ មានការជជែកវែកញែកជាច្រើន អំពីសិទ្ធិរបស់សហគមន៍ជនជាតិដើម ក្នុងការធ្វើរ៉ែជាលក្ខណៈសិប្បកម្ម ដោយសារសកម្មភាពទាំងនោះ អាចជាប្រពៃណីរបស់ពួកគេជាច្រើនជំនាន់មកហើយ តើនេះជា □ការជីករករ៉ែខុសច្បាប់ដែរ ឬយ៉ាងណា□។

**សមាគមអ្នកម៉ៅការខួងអណ្តូងរ៉ែអន្តរជាតិ** (International Association of Drilling Contractors/IDAC): សមាគមអាជីវកម្មមួយដែលតំណាងឲ្យផលប្រយោជន៍របស់សមាជិកនៃផ្នែកខួងអណ្តូងរ៉ែនៃឧសហាកម្មរ៉ែលោហៈ និងឧស្ម័ន។ សមាគមនេះផ្តល់ជាឯកសារបោះពុម្ពផ្សាយទាក់ទងនឹងរបៀបធ្វើឧសហាកម្មដែលបានផ្តល់ជាអនុសាសន៍ និងឯកសារបណ្តុះបណ្តាលផ្សេងៗទៀត។

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (International Monetary Fund/IMF): IMF គឺជា

អង្គការអន្តរជាតិមួយមានប្រទេសចំនួន១៨៣ជាសមាជិក ត្រូវបានបង្កើតឡើង ដើម្បីជំរុញកិច្ចសហប្រតិបត្តិផ្នែករូបិយវត្ថុអន្តរជាតិ ស្ថេរភាពនៃការដោះដូរ និង ការរៀបចំការដោះដូរឲ្យមានរបៀបរៀបរយ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និង កម្រិតការងារឲ្យបានខ្ពស់ និងដើម្បីផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុជាបណ្តោះអាសន្ន ដល់ប្រទេសនានា ដើម្បីជួយសម្រួលតុល្យភាពនៃការកែសម្រួលការបង់ប្រាក់។

**អណ្តូងចាក់បញ្ចូលទឹក ឬឧស្ម័ន** (Injection Well): ត្រូវគេប្រើដើម្បីចាក់បញ្ចូលទឹក ឬឧស្ម័នដើម្បីរក្សាបណ្តុំសម្ពាធ ឬដាក់ឲ្យស្ថិតក្រោមសម្ពាធ។

**ការទូទាត់ជាវត្ថុ** (In-kind Payments): គឺជាចំណាយធ្វើឡើងចំពោះរដ្ឋាភិបាល (ឧទា: កម្រៃជាដើម) ជាទម្រង់របស់របរប្រើប្រាស់ជាក់ស្តែង (ឧទា. ប្រេងឥន្ធនៈ ឧស្ម័ន រ៉ែជាដើម) ជំនួយឲ្យសាច់ប្រាក់។

**បទដ្ឋានគណនេយ្យអន្តរជាតិ** (International Accounting Standards): គឺជា បទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិ សម្រាប់ការធ្វើរបាយការណ៍ហិរញ្ញវត្ថុដែល ចេញដោយក្រុមប្រឹក្សាភិបាល បទដ្ឋានគណនេយ្យអន្តរជាតិ។ ការប្រើប្រាស់ បទដ្ឋានទាំងនេះ នៅក្នុងប្រទេសនីមួយៗ គឺស្រេចលើអង្គភាពដែលពាក់ព័ន្ធនៅ ក្នុងប្រទេសនោះ។

**ដែក** (Iron)៖ គឺជាលោហធាតុមានពណ៌សទឹកប្រាក់ទន់ ធ្ងន់ អាចឆក់ មានភាព យឺ ដែលអាចច្រេះស៊ីនៅក្នុងខ្យល់មានសំណើម និងមានកម្លាំងឆក់ ឬឆក់។ រ៉ែនេះ ឃើញមាននៅក្នុងសិលាភ្នំភ្លើង។ ជាលោហធាតុដែលគេប្រើប្រាស់ជាទូទៅបំផុត រ៉ែលោហៈ គឺជាផ្នែកមួយនៃការសាងសង់គ្រឿងចក្រ និងឧបករណ៍គ្រឿងម៉ាស៊ីន រថយន្ត គ្រោងនាវា និងរចនាសម្ព័ន្ធអគារ ព្រមទាំងសម្រាប់ជាគ្រឿងសង្ហារឹម ប្រដាប់ប្រដារផ្ទះបាយ និងសម្ភារៈការិយាល័យជាដើម។ រ៉ែដែក ក៏ត្រូវប្រើប្រាស់ នៅក្នុងការផលិតសម្លៀកបំពាក់ កៅស៊ូ ថ្នាំលាប ថ្នាំសម្លាប់សត្វល្អិត និងចំណី សត្វផងដែរ។

# J

**មុខតំណ** (Joint): ផ្ទៃរាប ឬផ្ទៃបែងចែក ដែលខណ្ឌសិលា ហើយដែលតាម

បណ្ដោយចន្លោះ ខណ្ឌនោះគ្មានចលនាដែលអាចមើលឃើញ ស្របទៅនឹងផ្ទៃរាបទេ។

# K

**ចាប់ផ្ដើម** (Kick-off):

១.ការដាក់អណ្ដូងរ៉ែមួយឲ្យចាប់ផ្ដើមផលិតកម្ម គេប្រើពាក្យនេះញឹកញាប់បំផុតនៅពេលគេចាក់បញ្ចូលឧស្ម័នទៅក្នុងអណ្ដូងយោងឧស្ម័ន ដើម្បីចាប់ផ្ដើមផលិតកម្ម។ ២. នៅក្នុងកិច្ចការប្រតិបត្តិការប្រេង មានន័យថា ដុសលាងអណ្ដូងរ៉ែមួយ ដើម្បីស្ដារវាឲ្យមានផលិតកម្មវិញ។ ៣. មានន័យថា ផ្លាស់ប្ដូរទិសដៅអណ្ដូងពីខ្សែបញ្ឈរ ដូចនៅក្នុងការខួងអណ្ដូងរ៉ែ តាមទិសដៅ។

# L

**ស្ថានីយ៍ខួងអណ្ដូងរ៉ែលើដីគោក** (Land Rig): គឺជាកន្លែងខួងប្រេង មានទីតាំងនៅលើដីគោក។

**សណ្ឋានដី** (Landscape): គឺជាទម្រង់ដី ឧទា. ទីទួល ភ្នំ វាលទំនាបលិចទឹក វាលខ្សាច់ ជ្រលងភ្នំ បឹង ជាដើម។

**បំណាក់ដី** (Landslide): គឺជាបាតុភូតភូគព្ភសាស្ត្រ រួមមានដូចជាចលនាដីជាច្រើន ដូចជា ការធ្លាក់ថ្ម ការបាក់ធ្លាក់យ៉ាងជ្រៅនៃចំណោត និងលំហូរកំទេចកំទីរាក់ៗជាដើម។ កម្លាំងជំរុញជាចម្បងនៃបំណាក់ដី គឺទំនាញផែនដី រួមផ្សំជាមួយភាពគ្មានលំនឹងនៃចំណោតនិងកត្តាជំរុញមួយចំនួនទៀត ដូចជាការផ្ទុះ ឬរំញ័រនៃសំណង់បញ្ចេញជាជំនន់ផែនដី។ ហៅម្យ៉ាងទៀតថា □ការរអិលដី□ បំណាក់ដីគឺមានលក្ខណៈដូចជាការរអិលធ្លាក់នៃភក់ ឬដី។

**ឧស្ម័នតេលសិលារាវ** (Liquid Petroleum Gas/LPG): គឺជាប្រភេទប្រេងឥន្ធនៈជំនួសឲ្យឧស្ម័នបុរាណ។ LPG មានសមាសភាគទៅដោយឧស្ម័ន ប្រូប៉ាន ប្រូពីឡែន ប៊ុយតាន និងប៊ុយទីឡែន នៅក្នុងល្បាយផ្សេងៗ។

**ការលាយកំបោរ** (Liming)៖ គឺជាដំណើរការឧស្សាហកម្ម ដែលគេប្រើដើម្បីកាត់បន្ថយចំណុះអាស៊ីដនៃសំណល់រ៉ែ និងដើម្បីរក្សាលំនឹងការបង្ហូរជារួមនៃបរិស្ថានជុំវិញ។

**ស្រទាប់រ៉ែមានតម្លៃ** (Lode)៖ គឺជាស្រទាប់រ៉ែដ៏មានតម្លៃនៃរ៉ែលោហៈ នៅជាប់នឹងក្រហែងសិលា ឬសំណាកសិលា ឬជាស្រទាប់ដែលកប់នៅក្នុងសំណាកសិលា។

**ប្រេងរំអិល** (Lubes/lubricants)៖ ផលិតផលដែលបានចម្រាញ់ឲ្យមានសភាពខាប់ជាង ស្អិតអន្ទិលជាងផលិតផលដទៃទៀត ដូចជាប្រេងរំអិលម៉ាស៊ីនម៉ូតូ ប្រេងបាដាង ឬប្រេងម៉ាស៊ីនជាដើម។

# M

**អនុស្សរណៈនៃការយោគយល់** (Memorandum of Understanding/MOU)៖ គឺជាឯកសារពណ៌នាអំពីការព្រមព្រៀងទ្វេភាគី ឬពហុភាគី រវាងភាគីនានា។ ឯកសារនេះបង្ហាញអំពីការព្រមព្រៀងតាមឆន្ទៈ រវាងភាគីនានា បញ្ជាក់អំពីខ្សែបន្ទាត់រួមនៃវិធានការដែលបានគ្រោងទុក។

**លោហធាតុ** (Metal)៖ គឺជាវត្ថុរឹង ដែលពិបាកបំបែក មានពន្លឺ មានសភាពយឺត អាចរំលាយបាន និងអាចហូតជាសរសៃបាន មានកុងដង់សាតេអេឡិចត្រូនិក និងចម្លងកម្តៅបានល្អ។

**លោហស្សាហកម្ម** (Metallurgy)៖ វិស័យវិទ្យាសាស្ត្រសម្ភារៈមួយដែលសិក្សាអំពីចរិតលក្ខណៈផ្នែករូបវិទ្យា និងគីមីវិទ្យារបស់អង្គធាតុលោហៈ និងសមាសភាគរបស់វា។ វាក៏ជាបច្ចេកវិទ្យា លោហធាតុផងដែរ ពោលគឺជារបៀបដែលវិទ្យាសាស្ត្រត្រូវបានអនុវត្តនៅក្នុងបម្រើបម្រាស់ជាក់ស្តែងរបស់វា។

**រ៉ែលោហៈ** (Metallic Minerals)៖ រ៉ែដែលមានផ្ទុកលោហធាតុ ដូចជាមាស ដែក សំណ ទង់ដែង និងលោហធាតុដទៃទៀត ស្ថិតនៅក្នុងទម្រង់ខាប់។ រ៉ែលោហៈត្រូវតែបំបែកចេញពីគ្នា និងកែច្នៃតាមបែបគីមីដើម្បីទាញយកលោហធាតុមានប្រយោជន៍ពីរ៉ែ។

**សិលាប្រែក្លាយរូបរាង** (Metamorphic rock): គឺជាប្រភេទសិលាមួយប្រភេទក្នុងចំណោមប្រភេទសិលាទាំងបីសំខាន់ៗ (ប្រភេទសិលាដទៃទៀតមាន សិលាភ្នំភ្លើង និងសិលាល្បប់)។ សិលាប្រែក្លាយរូបរាងកកើតឡើងពីសិលារឹងដែលមានពីមុនមកស្រាប់ ដោយការផ្លាស់ប្តូរផ្នែករ៉ែវិទ្យា រចនាសម្ព័ន្ធ និងគីមីវិទ្យា ជាការឆ្លើយតបចំពោះការផ្លាស់ប្តូរខ្លាំងពេកនៅក្នុងសីតុណ្ហភាព សម្ពាធ និងទម្ងន់កាត់ផ្តាច់។ ឧទាហរណ៍ដូចជាក្វាក្ស/ថ្មខៀវហានុមាន ថ្មម៉ាប និងថ្មបន្ទះ(slate) ជាដើម ដែលសិលាទាំងអស់នេះ ត្រូវបានគេធ្វើរ៉ែសម្រាប់បម្រើគោលបំណងផ្សេងៗ។

**ប្រតិបត្តិការផ្នែកកណ្តាល** (Midstream Sector): គឺជាផ្នែកមួយក្នុងចំណោមផ្នែកទាំងបីនៃប្រតិបត្តិការប្រេងឥន្ធនៈ និងឧស្ម័ន (ផ្នែកផ្សេងទៀត គឺប្រតិបត្តិការផ្នែកលើ និងផ្នែកក្រោម)។ប្រតិបត្តិការផ្នែកកណ្តាល គឺជាដំណើរការកែច្នៃ ស្តុកទុក និងដឹកជញ្ជូនប្រេងឥន្ធនៈ និងឧស្ម័ន។ សកម្មភាពផ្នែកកណ្តាល ជួនកាលត្រូវបានបញ្ចូលទៅក្នុងប្រតិបត្តិការផ្នែកក្រោមដែរ។

**សំណល់រ៉ែ** (Mine tailings)៖ ក្រោយពីរ៉ែដែលគេចង់បាន ត្រូវបានយកចេញពីកន្លែងធ្វើរ៉ែកាកសំណល់សិលានៅលើដីដែលនៅសល់ ឬហៅថា សំណល់រ៉ែ ត្រូវទុកចោលជាគំនរ។ សំណល់ដែលមានលោហធាតុធ្ងន់ៗ និងសារធាតុគីមីសម្រាប់កែច្នៃសំណល់រ៉ែធ្វើឲ្យខ្យល់អាកាស ទឹក និងដីនៅតំបន់ជុំវិញ។

**កម្មករជីករ៉ែ** (Miner)៖ គឺជាអ្នកដែលប្រឡូកនៅក្នុងអាជីវកម្ម ឬមុខរបរនិស្សារណកម្មរ៉ែលោហៈធ្យូងថ្ម សារធាតុមានតម្លៃ ឬវត្ថុធាតុដើមធម្មជាតិដទៃទៀត ពីសំបក/បំណែកផែនដី។

**រ៉ែ** (Mineral): សមាសភាគអសរីរាង្គ ដែលកើតមានឡើងតាមធម្មជាតិនៅលើសំបកផែនដីដែលមានគុណភាពផ្នែករូបវន្តខុសប្លែកពីគេ និងមានសមាសភាពគីមីជាក់លាក់មួយ។

**ស្រទាប់រ៉ែ** (Mineral Deposit): ស្រទាប់រ៉ែ គឺជាបាតុភូតកំហាប់ធម្មជាតិនៃរ៉ែមួយ ឬច្រើន។ ស្រទាប់រ៉ែអាចកើតមានឡើងនៅក្នុងសិលាប្រភេទណាមួយ ឬមានរ៉ែប្រភេទណាមួយ។

**ការរុករករ៉ែ** (Mineral Exploration)៖ ការរុករក ឬការជីករករ៉ែ គឺជាសកម្មភាពនៃការស្វែងរកដែនដី ដើម្បីស្រាវជ្រាវស្រទាប់រ៉ែលោហៈ បេង្រឥន្ធនៈ ឬឧស្ម័ន។

**អាជីវកម្មរ៉ែ** (Mineral Exploitation)៖ ប្រតិបត្តិការធ្វើរ៉ែ ទាក់ទងនឹងការប្រើប្រាស់បច្ចេកទេស និងសេដ្ឋកិច្ចនៃធនធានរ៉ែ រួមមានដូចជាការអភិវឌ្ឍរ៉ែ និស្សារណកម្មផលរ៉ែ ប្រព្រឹត្តកម្មរ៉ែការកែច្នៃរ៉ែ និងការទទួលផលធនធានរ៉ែ ព្រមទាំងសកម្មភាពដែលចាំបាច់ ឬទាក់ទងទៅនឹងការរកទីផ្សារសម្រាប់ធនធានរ៉ែទាំងនោះផងដែរ។

**ប្រភពរ៉ែ** (Mineral Reserves)៖ ធនធានដែលគេចាត់ទុកថា មានលទ្ធភាពផ្នែកសេដ្ឋកិច្ចសម្រាប់ធ្វើនិស្សារណកម្មប្រយោជន៍។ ប្រភពរ៉ែពិតប្រាកដ មានន័យថា សកម្មភាពភូគព្ភសាស្ត្រដែលបានអះអាងជាក់ស្តែងថា ពិតជាមានបរិមាណរ៉ែជាក់លាក់ចំណែកប្រភពរ៉ែប្រហាក់ប្រហែល មានន័យថា សកម្មភាពភូគព្ភសាស្ត្រ និងការធ្វើបញ្ជីសារពើភ័ណ្ឌ បញ្ជាក់អំពីអត្ថិភាពនៃរ៉ែ ប៉ុន្តែបរិមាណរបស់វា មិនត្រូវបានកំណត់ឲ្យបានត្រឹមត្រូវឡើយ។ (ហៅថា □ប្រភព□ ក៏បាន)។

**ការជីករករ៉ែ** (Mining)៖ និស្សារណកម្មរ៉ែមានតម្លៃ ឬសារធាតុរូបវន្តដទៃទៀតពីផែនដី តាមធម្មតាពីតួនៃរ៉ែលោហៈ សរសៃរ៉ែ ឬស្រទាប់ធ្យូងថ្ម។ ការធ្វើរ៉ែក្នុងន័យទូលាយ រាប់បញ្ចូលការទាញយកធនធានដែលមិនអាចប្រើប្រាស់វិញបានដូចជារ៉ែមាស សង្កសី ខ្សាច់ និងសិលា ប្រេងកាតព្រមទាំងទឹកផងដែរ។

**វិស្វករខាងរ៉ែ** (Mining Engineer)៖ បុគ្គលដែលមានគុណវុឌ្ឍិដោយសារការអប់រំការបណ្តុះបណ្តាល និងមានបទពិសោធន៍ផ្នែកវិស្វកម្មរ៉ែ។ វិស្វករដែលបានទទួលការបណ្តុះបណ្តាល មានជំនាញផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច និងសិល្បៈនៃការរករ៉ែ និស្សារណកម្មរ៉ែ ការប្រមូលផ្តុំរ៉ែ និងការលក់រ៉ែ ព្រមទាំងមានចំណេះដឹងអំពីបញ្ហារដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានសារៈសំខាន់ជាក់ស្តែងសម្រាប់ជីករករ៉ែឲ្យបានផលចំណេញ។

**ភតិសន្យាធ្វើរ៉ែ** (Mining Lease)៖ គឺជាកិច្ចសន្យាធ្វើរ៉ែណាមួយ និងនិស្សារណកម្មរ៉ែ ឬស្រទាប់រ៉ែដទៃទៀតពីកិច្ចសន្យានោះតាមលក្ខខណ្ឌជាក់លាក់។ ហៅម្យ៉ាងទៀតថា ភតិសន្យារ៉ែ(mineral lease)។

**ប្រតិបត្តិការអាជីវកម្មរ៉ែ** (Mining Operations): កិច្ចការដែលធ្វើឡើងក្នុងដំណើរការនៃអាជីវកម្មរ៉ែ រួមមានដូចជា ការរុករករ៉ែ ការចម្រាញ់រ៉ែ ការទទួលផល និងការកែច្នៃរ៉ែ។

**អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មរ៉ែ** (Mining Permit or License): ការទទួលស្គាល់ ឬការអនុញ្ញាតជាផ្លូវការ ដើម្បីធ្វើរ៉ែនៅក្នុងស្រទាប់រ៉ែមួយ។ ឯកសារនេះផ្តល់សិទ្ធិស្របច្បាប់ដល់អ្នកធ្វើរ៉ែ ដើម្បីធ្វើនិស្សារណកម្មរ៉ែ។

**ក្រសួងបរិស្ថាន** (Ministry of Environment/MoE): នៅប្រទេសកម្ពុជា ក្រសួងនេះទទួលខុសត្រូវចំពោះកិច្ចការពារបរិស្ថាន។ ទំនួលខុសត្រូវនេះរួមមាន ការព្រាងច្បាប់ ការអនុវត្ត និងការពង្រឹងច្បាប់ទាក់ទងនឹងបរិស្ថាន និងការវាយតម្លៃរបាយការណ៍ EIA។

**ក្រសួងរ៉ែ ឧស្សាហកម្ម និងថាមពល** (Ministry of Mines, Industry and Energy/MIME): នៅប្រទេសកម្ពុជា ក្រសួងនេះទទួលខុសត្រូវចំពោះកិច្ចការទាក់ទងនឹងការធ្វើរ៉ែ។ ទំនួលខុសត្រូវនេះ រួមមានការព្រាងច្បាប់ ការអនុវត្ត និងការពង្រឹងច្បាប់ទាក់ទងនឹងការធ្វើរ៉ែ ការអនុម័ត និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែ និងការត្រួតពិនិត្យប្រតិបត្តិការធ្វើរ៉ែ។

**សិលាមេ (ឬសិលាប្រភព)** Mother (or source) rock: សិលាដើមដែលគេរកឃើញរ៉ែនៅក្នុងនោះ។ ចំពោះប្រេង នេះជាសិលាល្បប់ដែលបានកកផ្តុំគ្នាជាមួយសារធាតុសរីរាង្គរយៈពេលជាយូរ ក្លាយជាអ៊ីត្រូកាបូន (ឧស្ម័ន និងប្រេង)។ ហៅម្យ៉ាងទៀតថា □សិលាបា□

**ការរំលាយកំពូលភ្នំ** (Mountain-top removal): ជាទម្រង់នៃការធ្វើរ៉ែប្រកបដោយវាទប្បដិវាទ ដោយប្រើគ្រឿងផ្ទុះ ដើម្បីបំផ្ទុះកំពូលភ្នំចេញ ដើម្បីយករ៉ែ ឬសិលានៅក្រោមដី។ វិធីនេះ ទាក់ទងច្រើនបំផុតជាមួយនឹងការធ្វើរ៉ែធ្យូងថ្ម។ ការរំលាយកំពូលភ្នំ មានផលប៉ះពាល់ផ្នែកបរិស្ថានខ្លាំងណាស់ ដូចជាការបំផ្លាញព្រៃឈើ ការបាត់បង់ជីវចម្រុះ ការបំផ្លាញស្ទឹង ឬទន្លេជាប្រភពទឹក ព្រមទាំងមានហានិភ័យចំពោះសុខភាពមនុស្ស និងសត្វ បណ្តាលមកពីជាតិពុលនៅក្នុងទឹក និងខ្យល់ និងធូលីដែលមានជាតិអាស៊ីដ ជាដើម។ ផលប៉ះពាល់ទាំងនេះមួយ

ចំនួនតូចអាចសម្រាលបាន។

# N

**ឧស្ម័នធម្មជាតិ** (Natural Gas): ប្រេងក្នុងទម្រង់ជាឧស្ម័ន ដែលមានអ៊ីដ្រូកាបូនស្រាលជារឿយៗ ឃើញមានជាប់ជាមួយប្រេងឥន្ធនៈ។ សារធាតុមេតាន គឺជាផ្នែកដ៏សំខាន់។

**នីកែល** (Nickel): លោហធាតុមានពណ៌ប្រាក់ រឹង អាចហូតជាសរសៃបាន មានជាតិដែកម៉ាញេទិក ដែលគេប្រើក្នុងសំលោហៈ ដើម្បីផលិតមេដែក និងកាក់ប្រាក់។ នីកែលស៊ុលហ្វីដ បានមកពីនីកែត ត្រូវគេប្រើសម្រាប់ធ្វើបន្ទុកអគ្គិសនី ឬអាគុយដែលអាចបញ្ចូលភ្លើងវិញបាន។

**ឧស្ម័នសុទ្ធ** (Non-associated gas): ឧស្ម័នធម្មជាតិ ដែលឃើញមាននៅក្នុងអាងរ៉ែធម្មជាតិ ដែលមិនមានផ្ទុកប្រេងនៅ។

**រ៉ែគ្មានលោហធាតុ** (Non-metallic minerals): រ៉ែដែលគ្មានផ្ទុកដែក មានតម្លៃសម្រាប់បម្រើផលប្រយោជន៍ឧស្សាហកម្ម និងសំណង់។ រ៉ែទាំងនេះរួមមាន ស៊ុលហ្វាត ខ្សាច់ស៊ីលីកាដីឥដ្ឋ ដូឡូមីត ក្រាហ្វីត ហ្វ្លូអូរីត និងត្បូងថៃ (zircon)។

**ថាមពលមិនអាចកកើតវិញបាន** (Non-renewable energies): ផូស៊ីលឥន្ធនៈ ដូចជា ប្រេងសាំង ធ្យូងថ្ម ឧស្ម័នធម្មជាតិ និងប្រេងរំអិល ដែលអាចធ្វើនិស្សារណកម្មបានតែម្តងរួចហើយមិនអាចកើតមានជាបន្ថែមបាន។ ជាប្រភេទធនធានដែលមិនអាចធ្វើឲ្យកើតមានឡើងវិញបាន។

**ធនធានមិនអាចកកើតវិញបាន** (Non-renewable resource): ធនធានដែលមិនអាចផលិត ដាំដុះឡើងវិញ បង្កើតសារជាថ្មី ឬប្រើប្រាស់ឡើងវិញក្នុងកម្រិតមួយដែលអាចទ្រទ្រង់អត្រាបម្រើបម្រាស់របស់វាបាន។ ធនធានទាំងនេះកើតមានក្នុងកម្រតិថេរមួយ គេអាចបានត្រឹមតែធ្វើនិស្សារណកម្មប៉ុណ្ណោះ ហើយមិនអាចធ្វើឲ្យកើតមានជាបន្ថែមបានឡើយ។ ធនធានទាំងនេះរួមមានដូចជា ផូស៊ីលឥន្ធនៈ ដូចជាប្រេង ធ្យូងថ្ម ឧស្ម័នធម្មជាតិ និងរ៉ែ ដូចជា ទង់ដែង ហ្វស្វ័រ ជាដើម ។ល។ ធនធានមិនកកើតវិញបាន មិនអាចមាននិរន្តរភាពជារៀងរហូតឡើយ។

# O

**អណ្តូងរ៉ែក្នុងសមុទ្រ** (Offshore Well): ការដ្ឋាន និងរោងចក្រផលិតប្រេងដែលសាងសង់នៅក្នុងសមុទ្រ។

**ប្រេង** (Oil): ល្បាយរាវមានលក្ខណៈសាមញ្ញ ឬស្មុគ្រស្មាញ នៃអ៊ីដ្រូកាបូន ដែលអាចចម្រាញ់ឲ្យបានទិន្នផលជាប្រេងសាំង ប្រេងកាត ប្រេងរំអិល និងផលិតផលផ្សេងៗទៀត។

**វាលប្រេង ឬឧស្ម័ន** (Oil and Gas Fields): វាល ឬអាងដ៏ធំ ដែលមានផ្ទុកទាំងប្រេងទាំងឧស្ម័នធម្មជាតិ រាប់បញ្ចូលបរិមាណទាំងមូល មិនមែនគ្រាន់តែប្រភពរ៉ែដែលអាចស្តារឡើងវិញបានតែប៉ុណ្ណោះទេ។

**វាលប្រេង** (Oilfield): ផ្ទៃរាបខាងលើដែលគ្របដណ្តប់លើអាងប្រេង។ តាមធម្មតាពាក្យនេះ មានន័យរាប់បញ្ចូលមិនមែនតែផ្ទៃរាបខាងលើប៉ុណ្ណោះទេ ប៉ុន្តែក៏រាប់បញ្ចូលទាំងអាងរ៉ែ អណ្តូងរ៉ែ និងបរិក្ខារផលិតកម្មផងដែរ។

**រោងចក្រចម្រាញ់ប្រេង** (Oil Refinery): សម្ភារៈបរិក្ខារសម្រាប់កែច្នៃប្រេងឆៅឲ្យក្លាយជាប្រេងដែលអាចប្រើប្រាស់បាន និងផលិតផលដទៃទៀត។

**ប្រភពប្រេង** (Oil Reserves): បរិមាណនៃប្រេងដែលគេបានប៉ាន់ស្មានថាមាននៅក្នុងវាលប្រេងឬដែនដី ឬតំបន់ណាមួយនៃប្រទេសដែលអាចយកបានតាមបច្ចេកវិទ្យា និងលទ្ធភាពដែលគេចេះដឹង។

**ចំណតស្តុកប្រេង** (Oil Terminal): ឃ្លាំង ឬស្ថានីយ៍ដែលគេផ្ទុកប្រេង។ ហៅម្យ៉ាងទៀតថា ស្ថានីយ៍ប្រេង ឃ្លាំងប្រេង ស្ថានីយ៍បូមប្រេង ឬស្ថានីយ៍បង្កើនគុណភាពប្រេង ( booster sta-tion )។

**អណ្តូងប្រេង** (Oil Well): អណ្តូងដែលគេទទួលបានប្រេង។

**អាជ្ញាប័ណ្ណរុករកប្រេង** (Oil Exploration License/OEL): អាជ្ញាប័ណ្ណដែលផ្តល់សិទ្ធិមានកំណត់ទៅឲ្យអ្នកទទួលអាជ្ញាប័ណ្ណ ដើម្បីរុករកប្រេងកាតនៅក្នុងតំបន់

ជាក់លាក់ដែលពុំទាន់មានផ្តល់អាជ្ញាប័ណ្ណរករ៉ែ ឬភតិសន្យាធ្វើរ៉ែផ្សេងទៀត។

**ភតិសន្យាធ្វើរ៉ែប្រេង** (Oil Mine Lease/OML): កិច្ចព្រមព្រៀង ដែលផ្តល់សិទ្ធិស្របច្បាប់ទៅឲ្យក្រុមហ៊ុនមួយ ដើម្បីអភិវឌ្ឍ និងផលិតអ៊ីដ្រូកាបូនដែលបានរកឃើញនៅក្នុងតំបន់ជាក់លាក់មួយ ក្នុងរយៈពេលមួយជាក់លាក់។

**ភតិសន្យារកប្រេង** (Oil Prospecting Lease): កិច្ចព្រមព្រៀង ដែលផ្តល់សិទ្ធិស្របច្បាប់ទៅឲ្យក្រុមហ៊ុនមួយដើម្បីរុករកអ៊ីដ្រូកាបូន នៅក្នុងតំបន់ជាក់លាក់មួយក្នុងរយៈពេលមួយជាក់លាក់។

**អណ្តូងរ៉ែដីគោក** (Onshore Well): អណ្តូងប្រេង ឬអណ្តូងឧស្ម័ន ស្ថិតនៅក្នុងព្រំដែនដីគោកនៃប្រទេសមួយ។

ការ**ធ្វើរ៉ែអណ្តូងចំហ** (Open-pit mining): វិធីសាស្ត្រនិស្សារណកម្មរ៉ែ ដែលរកឃើញនៅជិតផ្ទៃលើនៃផែនដី ដោយប្រើការជីកចុះទៅក្នុងផែនដីពីផ្ទៃលើនៃផែនដី។ ជារឿយៗ រ៉ែក្នុងអណ្តូងចំហគ្របដណ្តប់តំបន់ដ៏ធំមួយ។

**រ៉ែអណ្តូងចំហ** ឬរ៉ែផ្ទៃលើ (Open-pit mine or open-cast mine): គឺជាការធ្វើរ៉ែផ្ទៃលើនៃផែនដី ដែលក្នុងនោះ សិលា ឬរ៉ែ ត្រូវធ្វើនិស្សារណកម្មពីផែនដីតាមរយៈអណ្តូងចំហ ឬរណ្តៅធំមួយ ( ហៅម្យ៉ាងទៀតថា “borrow.” )។ ការធ្វើរ៉ែអណ្តូងចំហតម្រូវឲ្យមានការជីកយកចេញនូវសំបកផែនដីនៅលើផ្ទៃដីយ៉ាងធំ ដោយបង្កឲ្យមានផលវិបាកបំផ្លិចបំផ្លាញចំពោះប្រព័ន្ធបរិស្ថានជុំវិញ។

**ប្រភពរ៉ែលោហៈ** (Ore reserves): បរិមាណ និងកម្រិតនៃរ៉ែលោហៈ ដែលក្រុមហ៊ុនមួយគណនាថា អាចធ្វើនិស្សារណកម្មបាន។ បរិមាណរ៉ែ អាចធ្វើចំណាត់ថ្នាក់ជា “អាចមាន”, “ប្រហែលមាន” និង “បញ្ជាក់ថាមាន” ប្រភពរ៉ែ យោងតាមទិន្នន័យដែលអាចរកបាន។

**បន្ទុកពីលើ** (Overburden): គឺជាដីផ្ទៃខាងលើ ដែលត្រូវយកចេញ ដើម្បីទទួលបានស្រទាប់ថ្មដ្យូងថ្ម និងស្រទាប់រ៉ែ។

# P

**ប្រេងប៉ារ៉ាហ្វីន** (Paraffin): សារធាតុគ្មានក្លិន គ្មានរសជាតិ គ្មានចលនាបែបគីមី មានលក្ខណៈដូចក្រមួនបានមកពីការចម្រាញ់ប្រេងកាត ជាសារធាតុមានសភាពភ្លឺថ្លា អាចឆាបឆេះ មានសមាសភាគទៅដោយអ៊ីដ្រូកាបូនឆ្អែតទឹក។

**ភាពជ្រាបទឹក** (Permeability): រង្វាស់សមត្ថភាពរបស់វត្ថុធាតុស្ពោត (ជារឿយៗគឺជា សិលា ឬវត្ថុធាតុគ្មានកំហាប់) ដែលអនុញ្ញាតឲ្យវត្ថុរាវឆ្លងកាត់វា។ សិលាអាចមានរន្ធ ឬចន្លោះទំនេរ នៅខាងក្នុង (រន្ធញើស) ជាច្រើន ដែលអនុញ្ញាតឲ្យវត្ថុរាវហូរឆ្លងកាត់ នេះមានន័យថា សិលានោះមានភាពជ្រាបទឹក។ ប្រសិនរន្ធទាំងនេះមិនជាប់គ្នា លំហូរវត្ថុរាវអាចត្រូវកាត់បន្ថយជាច្រើន មានន័យថា សិលានេះ មិនសូវមានភាពជ្រាបទឹក ឬមិនអាចជ្រាបទឹកបានទៀតផង (មានន័យថា គ្មានលំហូរវត្ថុរាវទាល់តែសោះ។

**លិខិតអនុញ្ញាត** (Permit): ទាក់ទងនឹងការធ្វើរ៉ែ វាជាឯកសារមួយដែលចេញដោយទីភ្នាក់ងារនិយ័តកម្ម ដែលផ្តល់ការយល់ព្រមចំពោះប្រតិបត្តិការធ្វើរ៉ែឲ្យប្រព្រឹត្តទៅបាន។

**តេលសិលាគីមី** (Petrochemicals): សារធាតុគីមី ដូចជាអេទីឡែន ប្រូពីឡែន និងបង់ហ្សែនបានមកពីប្រេងកាតឆៅឬតេលាសិលា។ជារឿយៗសារធាតុទាំងនេះត្រូវបានផលិតឡើងជាផ្នែកមួយនៃដំណើរការចម្រាញ់ប្រេង។

**តេលាសិលា** (Petroleum): ជាវត្ថុរាវមានជាតិប្រេងរំអិលអាចឆាបឆេះ មានពណ៌ប្រែប្រួលពីលឿងដល់ខ្មៅ មានផ្ទុកអ៊ីដ្រូកាបូនខុសគ្នាជាខ្លាំង ឃើញមាននៅក្នុងស្រទាប់ល្បប់នៃសំបកផែនដី។

**ប្រេងឥន្ធនៈ** (Petroleum Fuels): ប្រេងសាំង និងប្រេងរំអិល។

**ការធ្វើតេស្តធាតុពុល** (Phytotoxicity test): ការប៉ាន់ប្រមាណសារធាតុគីមីពុលដែលឃើញមាននៅក្នុងដីដូចជា សារធាតុដែលបញ្ចេញទៅក្នុងបរិស្ថានដោយនិស្សារណកម្មរ៉ែ និងដំណើរការរំលាយរ៉ែជាដើម។

**ឧស្ម័នសម្រាប់បង្ហូរតាមបំពង់បង្ហូរ** (Pipeline Gas): ឧស្ម័នស្ថិតក្រោមសម្ពាធគ្រប់គ្រាន់ ដើម្បីបញ្ចូលទៅក្នុងបំពង់បង្ហូរឧស្ម័នដែលមានសម្ពាធខ្ពស់របស់អ្នកទិញឧស្ម័ន។ ឧស្ម័នដែលមានរំហួតគ្រប់គ្រាន់ ដើម្បីកុំឲ្យអ៊ីដ្រូកាបូនរាវ ដូចជា ឧស្ម័នធម្មជាតិ ប៊ុយតាន និងវត្ថុរាវជាឧស្ម័នដទៃទៀត ដែលតាមធម្មតាមាននៅក្នុងឧស្ម័នធម្មជាតិក្លាយជាខាប់ ឬកកធ្លាក់នៅក្នុងបំពង់បញ្ជូន ឬបង្ហូរ។

**ប្លាទីន** (Platinum): អង្គធាតុលោហៈមានតម្លៃពណ៌ប្រាក់លាយស អាចហូតជាសរសៃបានច្រេះមិនស៊ីធ្ងន់ អាចកិនជាសន្លឹកដែលគេប្រើប្រាស់ក្នុងឧបករណ៍គ្រប់គ្រងរំភាយរថយន្ត ម៉ាស៊ីន គ្រឿងអេឡិចត្រូនិក និងកាតាលីករ (ជាពិសេសសម្រាប់ការផលិតប្រេងកាត) ព្រមទាំងគ្រឿង និងបរិធានគីមីផ្សេងៗទៀត។ វាជាផ្នែកជាទូទៅមួយនៅក្នុងនាវា ផៃដែក និងបំពង់បង្ហូរប្រេង ព្រមទាំងសំលោហៈសម្រាប់បម្រើការផ្នែកទន្តសាស្ត្រ និងគ្រឿងអលង្ការផងដែរ។

**ភាពស្ពោត** (Porosity): រង្វាស់ទំហំនៃចន្លោះទំនេរនៅក្នុងសិលាធៀបនឹងទំហំសិលាទាំងមូល។ ចន្លោះ ឬរន្ធញើសទាំងនេះ ជាកន្លែងដែលប្រេង ឬឧស្ម័នស្ថិតនៅ ដូច្នេះជាទម្រង់មួយដែលមានភាគរយនៃភាពស្ពោតខ្ពស់អាចមានអ៊ីដ្រូកាបូនកាន់តែច្រើន។

**យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ** (Poverty Reduction Strategy/PRS): យុទ្ធសាស្ត្រដែលរៀបចំឡើងនៅថ្នាក់ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ។ ការងារនេះមានបំណងធានាឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធឲ្យបានទូលំទូលាយក្នុងការរៀបចំយុទ្ធសាស្ត្រ កែលម្អកិច្ចសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងផ្តោតលើការប្រមូលផ្តុំធនធានរបស់សហគមន៍អន្តរជាតិ ដើម្បីសម្រេចគោលដៅកាត់បន្ថយភាពក្រីក្រ។

**លោហធាតុស្ពោត** (Precious Metal): អង្គធាតុគីមីមានលោហធាតុដែលកើតឡើងតាមធម្មជាតិដ៏កម្រ មានតម្លៃផ្នែកសេដ្ឋកិច្ច។ លោហធាតុស្ពោត មានប្រតិកម្មតិចជាងអង្គធាតុភាគច្រើនបំផុត មានភាពរលោងខ្លាំង មានសភាពទាន់ជាង ឬងាយហូតជាសរសៃជាង និងមានចំណុចរលាយខ្ពស់ជាងលោហធាតុដទៃទៀត។ តាមប្រវត្តិសាស្ត្រ លោហធាតុមានតម្លៃបានបម្រើតួនាទីជារូបិយប័ណ្ណ ឬស្តង់ដាររូបិយប័ណ្ណ។ បច្ចុប្បន្ននេះ លោហធាតុទាំងនេះ គឺជារបស់ប្រើប្រាស់ និងវិនិយោគ

ដ៏មានសារៈសំខាន់បំពេញតួនាទីជាស្តង់ដាទីផ្សារ។ មាស ប្រាក់ និងប្លាទីន គឺជាឧទាហរណ៍នៃលោហធាតុមានតម្លៃ។

**អណ្តូងផលិតកម្មរ៉ែ** (Production Well): អណ្តូង (រន្ធដែលគេខួងចូលទៅក្នុងដី) ដែលគេប្រើសម្រាប់នាំប្រេង ឬឧស្ម័នចេញពីក្រោមដី។

**តំបន់អាចមានប្រេង**(Prospect): តំបន់ក្រោមដីដែលភូគព្ភវិទូគិតថា មានឱកាសអាចរកប្រេងបាន។

**ការរ៉ែង និងការរុករករ៉ែ** (Prospecting and Exploration): ការស្រាវជ្រាវ ការកំណត់ផែនទី និងការវាយតម្លៃភូគព្ភសាស្ត្ររបស់តំបន់មួយ ដោយប្រើវិធីសាស្ត្រភូគព្ភរូបវិទ្ធ និងវិធីសាស្ត្រភូគព្ភនាភីដើម្បីកំណត់បរិមាណ និងគុណភាពរបស់ប្រភពរ៉ែ ឬប្រេង/ឧស្ម័ន។ ការងារនេះ រាប់បញ្ចូលទាំងការខួង ការស្ទាបស្ទង់ ការធ្វើសំណាក ការវិភាគ ការធ្វើតេស្ត និងការកំណត់វិសាលភាពនៃលទ្ធភាពមានរ៉ែផងដែរ។

**ប្រភពបញ្ជាក់ថាមានរ៉ែ** (Proven Reserves): ប្រេង ឧស្ម័ន រឺរ៉ែលោហៈ ដែលបានរកឃើញ និងអាចយកបាន ប៉ុន្តែមិនទាន់ធ្វើនិស្សារណកម្មនៅឡើយ។

# Q

**ការត្រួតពិនិត្យគុណភាព** (Quality Control): ការធ្វើតេស្តផលិតផលទាំងអស់គ្រប់ពេលវេលាដើម្បីធានាថា ផលិតផលទាំងនោះ បំពេញតាមស្តង់ដាគុណភាពជាក់លាក់។

**ការដ្ឋានយកថ្ម** (Quarry): (នាម) ជាប្រភេទអណ្តូងរ៉ែចំហ ដែលគេធ្វើនិស្សារណកម្មថ្ម ឬរ៉ែពីក្នុងនោះ។ ការដ្ឋានយកថ្ម ជាទូទៅ គេប្រើប្រាស់សម្រាប់ធ្វើនិស្សារណកម្មសម្ភារៈសំណង់ដូចជាគ្រួសខ្សាច់ និងសិលា។ សម្ភារៈបរិក្ខារ សម្រាប់កែច្នៃថ្ម (ដូចជាម៉ាស៊ីនបំបែកថ្ម ជាដើម) ជារឿយៗ ត្រូវទុកដាក់នៅការដ្ឋានជាមួយគ្នាដែរ។ (ជាកិរិយាស័ព្ទ) មានន័យថា យក (ថ្ម) ឬសារធាតុក្នុងដីពីអណ្តូងរ៉ែចំហដោយការកាត់ ជីក ឬការបំផ្ទុះ។

# R

**សារធាតុវិទ្យុសកម្ម** (Radioactive Substance): វត្ថុធាតុណាដែលបញ្ចេញវិទ្យុសកម្ម។ អ៊ុយរ៉ាញ៉ូម និងថូរ្យូមគឺជាឧទាហរណ៍ ជាតួយ៉ាងនៃសារធាតុវត្ថុសកម្ម។

**កត្តាដែលអាចទាញយកផល** (Recovery Factor): ភាគរយនៃប្រេងកាតឬធនធានរ៉ែដទៃទៀតដែលមានតាំងពីដើមរៀងមកនៅក្នុងវាលប្រេងមួយ ដែលអាចទាញយកផលតាមរយៈនិស្សារណកម្ម។

**ឥណទេយ្យវិនិយោគចលនទ្រព្យ** (Real Estate Investment Trusts/REITs): ឥណទេយ្យ ឬសមាគមហិរញ្ញវត្ថុ ដែលវិនិយោគលើអចលនទ្រព្យផ្សេងៗ។ REITs គ្រប់គ្រងដោយប្រតិសិទ្ធិជនម្នាក់ឬច្រើននាក់ ដូចជាមូលនិធិសង្គហៈ និងមុខជំនួញដូចជាសញ្ញាប័ណ្ណដែរ។

**រោងចក្រចម្រាញ់ប្រេង** (Refinery): កន្លែង ( ដូចជារោងចក្រជាដើម ) ដែលប្រេងឆៅត្រូវគេបំបែក និងប្រែក្លាយឲ្យទៅជាផលិតផលដែលដោះដូរយកជាប្រាក់នៅក្នុងទីផ្សារបាន។

**ការចម្រាញ់** (Refining): ដំណើរការបង្វែរប្រេងឆៅឲ្យទៅជាផលិតផលប្រេងឥន្ធនៈដែលមានប្រយោជន៍។

**ថាមពលដែលអាចកកើតឡើងវិញបាន** (Renewable Energies): ថាមពលដែលបានមកពីធនធានធម្មជាតិ ដែលកើតមានដូចដើមវិញ ឬបង្កើតឡើងវិញតាមលក្ខណៈធម្មជាតិ។ ថាមពលទាំងនេះរួមមានដូចជា ពន្លឺព្រះអាទិត្យ ខ្យល់ ទឹកភ្លៀង និងជំនោរ/លំនាចនៃទឹក និងកម្ដៅផែនដី ជាដើម។ ក្នុងកម្រិតមានកំណត់មួយ ជីវម៉ាស និងជីវឥន្ធនៈ ដែលអាចកកើត ឡើងវិញតាមធម្មជាតិ ក៏អាចចាត់ទុកថាជាថាពលដែលអាចកកើតឡើងវិញបានដែរ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើការផលិតថាមពលទាំងនេះ បង្ហិនបង្ហោចធនធាន (ដូចជាដី ជាដើម) ក្នុងរបៀបមួយដែលមិនអាចមាននិរន្តរភាពយូរអង្វែង នោះវាមិនមែនជាថាមពលដែលអាចបង្កើតឡើងវិញបានទេ។ ថាមពលដែលបានមកពីទំនប់វារីអគ្គិសនីធំៗ អាចជា

ថាពលដែលអាចកកើតឡើងវិញបានប៉ុន្តែពិបាកនឹងចាត់ទុកថាថាមពល បែតង ណាស់ដោយសារការខូចខាតបរិស្ថាន ហើយជួនកាល សូម្បីតែឧស្ម័នផ្ទះកញ្ចក់ ក៏ពាក់ព័ន្ធនឹងថាមពលទាំងនេះដែរ។

**ធនធានដែលកកើតឡើងវិញបាន** (Renewable Resources): ធនធានធម្មជាតិដែលអាចកកើតឡើងវិញ ឬដែលកើតមានដូចដើមវិញ ជាធនធានដែលប្រើមិនចេះអស់។ ធនធានទាំងនេះរួមមានដូចជា សរីរាង្គមានជីវិត ដែលប្រើប្រាស់ដោយមនុស្ស ដើម្បីបម្រើគោលបំណងជាច្រើន(ដូចជាអាហារ ថ្នាំពេទ្យ សរសៃ ឥន្ធនៈ ។ល។) ដែលត្រូវជំនួសដោយដំណើរការធម្មជាតិ និងកើតមានឡើងវិញតាមកាលវេលា។ ធនធានដែលអាចកកើតឡើងវិញ គឺជាផ្នែកមួយនៃបរិស្ថានធម្មជាតិរបស់យើង និងបង្កើតបានជាប្រព័ន្ធអេកូឡូហ្ស៊ីរបស់យើង។ ធនធានទាំងនេះ អាចមាននិរន្តរភាពទៅបានតែក្នុងករណី ដែលវាអាចកើតមានឡើងវិញលឿនជាងការប្រើប្រាស់វាប៉ុណ្ណោះ។ ធនធានដែលអាចកកើតឡើងវិញមួយចំនួនកំពុងទទួលរងគ្រោះថ្នាក់ដោយសារការអភិវឌ្ឍឧស្សាហកម្ម និងអត្រានៃការប្រើប្រាស់ និងការលូតលាស់ខ្ពស់។ ធនធាននេះ រាប់បញ្ចូលទាំងថាមពលដែលអាចកកើតឡើងវិញដែលបានពណ៌នាខាងលើផងដែរ។

**ប្រភពរ៉ែ** (Reserves): បរិមាណទាំងឡាយនៃអ៊ីដ្រូកាបូន ឬរ៉ែ ដែលគេរំពឹងថា អាចទាញយកផលប្រយោជន៍ផ្នែកពាណិជ្ជកម្មបានពីកន្លែងប្រមូលផ្តុំនៃរ៉ែ ដែលគេបានរកឃើញ។

**អាងស្តុក** (Reservoir): កន្លែងកកើតសិលាល្បប់ ស្តោត មានរន្ធផ្ទុកទឹក ដែលមានបរិមាណប្រេង និង/ឧស្ម័ន បិទជិត ឬហ៊ុំព័ទ្ធដោយស្រទាប់សិលាមិនស្ទូវជ្រាបទឹក រឺមិនអាចជ្រាបទឹកចូលបង្កើតបានជាសិលារ៉ែមានលក្ខណៈជារចនាសម្ព័ន្ធ។

**ម៉ាស៊ីនខួងអណ្តូងប្រេង** (Rig): ដងថ្លឹងដែលមានរោងដាក់ម៉ាស៊ីនរបស់វា ដែលគេប្រើសម្រាប់ ខួងអណ្តូង បន្ទាប់មក បូមប្រេងចេញពីអណ្តូង។ ពាក្យនេះសំដៅទៅរកដងថ្លឹងខួងអណ្តូងប្រេងផ្ទាល់តែម្តង)។ (សូមមើលពាក្យ ដងយោងខួងអណ្តូងផងដែរ (derrick. )។

# S

**សំណាក** (Sample): បរិមាណសិលាមួយចំនួនតូចដែលគេបានយកចេញមកតាមធម្មតាដោយការចិត ឬច្រៀកយកសម្រាប់ធ្វើការវិភាគ។

**ល្បប់** (Sediments): ស្រទាប់ចុណ្ណភាគមានទំហំផ្សេងៗគ្នា បានមកពីការសំណឹកសិលាចាស់ ឬបណ្តាលមកពីសកម្មភាពផ្សេង (ដូចជាសំបកខ្យង ឬអ្វីផ្សេងទៀត)។ ល្បប់នេះ ក្លាយជាសិលាល្បប់ទៅតាមពេលវេលា។

**ណ្តាងល្បប់** (Sedimentary Basin): ដីដែលមានស្រទាប់ខាងលើនៃសិលាកើតឡើងពីធ្លាក់កកនៃល្បប់នៅលើតំបន់ធំមួយនៃមហាសមុទ្រ ឬបាតបឹង ក្នុងរយៈពេលជាច្រើនយុគសម័យភូគព្ភសាស្ត្រ។

**សិលាល្បប់** (Sedimentary Rock): សិលាល្បប់ គឺជាសិលាមួយប្រភេទក្នុងចំណោមសិលាទាំងបីប្រភេទធំៗ (ប្រភេទសិលាផ្សេងទៀត គឺសិលាកំអែភ្នំភ្លើង និងសិលាប្រែក្លាយរូបរាង)។ ទោះបីជាសិលាល្បប់ មានតែចំនួន៥%នៃសិលានៅក្នុងផែនដីក៏ដោយ ក៏សិលាប្រភេទនេះគ្របដណ្តប់ចំនួន៧៥%នៃផ្ទៃផែនដី។ ទឹកក្រោមដីស្ទើរតែទាំងអស់ និងស្រទាប់អ៊ីដ្រូកាបូន ឃើញមាននៅក្នុងសិលាល្បប់។ ខ្សាច់ និងគ្រួសគឺបានមកពីសិលាល្បប់។

សិលាល្បប់មានបីប្រភេទសំខាន់ៗ ប្រភេទនីមួយៗ កើតឡើងតាមរបៀបខុសគ្នា។

១. សិលាប្លាស្ទិក (Plastic rocks): សិលាដែលកើតឡើងដោយសារសំណឹក ឬការបក់ផាត់នៃខ្យល់អាកាសទៅលើសិលាដទៃទៀតឲ្យក្លាយជាល្បប់ (ចុណ្ណភាគតូចៗ រួចហើយវាក៏ធ្លាក់កកសារជាថ្មី និងប្រមូលផ្តុំនៅកន្លែងមួយផ្សេងទៀត។ឧទាហរណ៍: ថ្មភក់ឬថ្មខ្សាច់ និងថ្មស្បាល (shale)។

២. សិលាល្បប់សរីរាង្គ (Organic sedimentary rocks): សិលាដែលកើតមកពីសំណល់នៃរុក្ខជាតិ ឬសត្វក្នុងបរិមាណដ៏ច្រើន ដែលកប់ និងគាបសង្កត់នៅក្នុងក្រោមល្បប់សិលាមានក្លាយជាកាបូន។ឧទាហរណ៍ដូចជាថ្មកំបោរ និងធ្យូងថ្ម ជាដើម។

៣. សិល្បប់គីមី (Chemical sedimentary rocks): សិលាដែលកើតមកពី

ដំណើរការប្រតិកម្មគីមី កើតឡើងតាមធម្មជាតិ។ ដំណើរការប្រតិកម្មដ៏សាមញ្ញបំផុតនោះ គឺ តុរបាត ដែលតាមយៈនេះ រ៉ែត្រូវរលាយពីតួទឹករួច ហើយប្រមូលផ្តុំជាដុំរឹង នៅលើបាតសមុទ្រ ឬបាតបឹង។ ឧទាហរណ៍ៈ មនោសិលា ( ហៅម្យ៉ាងទៀតថា អំបិលយុគ/Epsom salts" )

**ការធ្វើរ៉ែប្រកបដោយការជ្រើសរើស** (Selective Mining): ជាដំណើរការមួយដែលតាមយៈនោះគេទទួលបានផលិតផលរ៉ែលំដាប់ថ្នាក់ខ្ពស់។ជាធម្មតា ការធ្វើរ៉ែរបៀបនេះ តម្រូវឲ្យមានការប្រើប្រាស់ប្រព័ន្ធទប់ដែលចំណាយខ្ពស់ ព្រមទាំងចំណាយរុករក និងអភិវឌ្ឍន៍ខ្ពស់ក្នុងការស្វែង និងការអភិវឌ្ឍបណ្តាញការងារដាច់ដោយឡែកការទំនាក់ទំនងប្រកបដោយភាពស្ទាត់ជំនាញខ្សែរយៈ និងបណ្តុំរ៉ែលោហៈ។

**ការបំបែក** (Separation): ដំណាក់កាលដំបូង ក្នុងការចម្រាញ់ប្រេងរួមមានការបំបែកអ៊ីត្រូកាបូនផ្សេងៗដែលមាននៅក្នុឆៅ អាស្រ័យទៅតាមកម្រិតពុះរបស់អ៊ីត្រូកាបូននីមួយៗ។

**កិច្ចសន្យាផ្តល់សេវា** (Service Contract)៖ ជាតួយ៉ាង កិច្ចសន្យាទាំងនេះ គឺជាកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍ ដែលផលិតប្រេង ឬក្រុមហ៊ុនជាតិរបស់ប្រទេសនោះនិងក្រុមហ៊ុនប្រេងឬ អ្នកម៉ៅការ ( តាមធម្មតាជាកម្មសិទ្ធិករបរទេស ) ដែលតាមរយៈនោះអ្នកម៉ៅការធ្វើការរុករក អភិវឌ្ឍន៍ដំណើរការផលិតក្នុងតំបន់នៃកិច្ចសន្យា ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ក្នុងនាមរដ្ឋាភិបាល ឬក្រុមហ៊ុនប្រេងជាតិរបស់រដ្ឋាភិបាល និងតាមការជ្រើសរើសរបស់រដ្ឋាភិបាល ឬក្រុមហ៊ុនប្រេងជាតិរបស់រដ្ឋាភិបាល។

**រូងអណ្តូងរ៉ែ** (Shaft): រន្ធដែលគេកាយរាងបញ្ឈរតូចចង្អៀត ឬជាជម្រាល ដើម្បីបើកផ្លូវ និងផ្តល់សេវាដល់អណ្តូងរ៉ែ។ តាមធម្មតា រូងនេះបំពាក់ដោយដងស្ទូចមួយនៅខាងលើដែលលើក និងដាក់យានសម្រាប់លើកដាក់មនុស្ស និងសម្ភារៈ។

**រូងអណ្តូងរ៉ែ** (Shaft Mine): គឺជាអណ្តូងរ៉ែក្រោមដី ដែលនៅក្នុងនោះមានច្រកចូលធំ ឬកន្លែងចេញចូល តាមរយៈរូងបញ្ឈរមួយ។

**ជំងឺស៊ីលីកូស៊ីស** (Silicosis): ជំងឺស្ងួតមិនអាចព្យាបាលបាន បណ្តាលមកពីការប៉ះ

ពាល់ដដែលៗជាមួយចុណ្ណភាគពុលនៃស៊ីលីកានៅក្នុងខ្យល់ និងកត់សម្គាល់ដោយការដុះដុំសាច់ និងជាលិកាស្នាមនៅក្នុងសួត។

**ប្រាក់** (Silver)៖ លោហធាតុមានពណ៌សថ្លា អាចហូតជាសរសៃបាន ទន់អាចហូតជាសន្លឹកបានមានកុងដង់សាតេចម្លងកម្ដៅ និងអគ្គិសនីខ្ពស់ជាងលោហធាតុទាំងអស់។

ចាត់ទុកជាលោហធាតុមានតម្លៃ ជារបស់ប្រើប្រាស់ និងវិនិយោគដ៏សំខាន់មួយ។ ប្រាក់ត្រូវគេប្រើសម្រាប់ធ្វើគ្រឿងអលង្ការ និងគ្រឿងតុបតែងកាយដទៃទៀត ចានសម ស្លាបព្រានិងកាក់ប្រាក់។ ប្រាក់ក៏ត្រូវគេប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ផ្ដិតជារូបភាព សំលោហៈលំអធ្មេញ និងសម្រាប់ផ្សាភ្ជាប់ ប្រើជាសៀគ្វីចាក់ពុម្ព ជាគ្រឿងអុបទិក ពិសេសការផលិតសម្លៀកបំពាក់ និងឧបករណ៍គ្រប់គ្រងនៅក្នុងម៉ាស៊ីនរីអាកទ័រនុយក្លេអ៊ែរទៀតផង។

**រន្ធដីស្រុត** (Sinkhole)៖ រន្ធដែលកើតជាធម្មជាតិ ឬការបាក់ស្រុតនៅក្នុងផ្ទៃដីបណ្ដាលមកពីការរលាយ ឬការបាក់ដំបូលរូងនៅក្រោមដី។ ជាទូទៅរន្ធទាំងនេះកើតមានឡើងនៅក្នុងតំបន់ថ្មកំបោរ ដែលទទួលរងឥទ្ធិពលពីការឡើងចុះនៃទឹកក្រោមដី។ រន្ធដីស្រុត ក៏អាចកើតមានឡើង នៅការដ្ឋានរ៉ែ ដែលគេលែងប្រើការ ឬបោះបង់ចោល ផងដែរ ដោយសារការបាក់ស្រុត និងការបាក់ធ្លាក់នៃរូងអណ្ដូងរ៉ែក្រោមដី។

**ឡស្លលោហធាតុ** (Smelter)៖ រោងចក្រសម្រាប់ស្លលោហធាតុពីរ៉ែនៃលោហធាតុនោះ។

**ស្ល** (Smelt)៖ រំលាយ ឬបំបែក (រ៉ែលោហៈ) ដើម្បីញែកសមាសភាគលោហៈ។

**ចង្ក្រានស្លលោហធាតុ** (Smelting Furnace)៖ ចង្ក្រាន – ឡដែលមានកម្រិតកម្ដៅខ្ពស់ដែលគេស្ល ឬកាត់បន្ថយរ៉ែលោហៈ។

**ទំនួលខុសត្រូវផ្នែកសង្គម** (Social responsibility)៖ កាតព្វកិច្ចរបស់រដ្ឋាភិបាលផ្នែកឯកជន និងសង្គមស៊ីវិលក្នុងការសម្រេចចិត្ត និងចាត់វិធានការដែលនឹងបង្កើនសុខមាលភាព និងផលប្រយោជន៍របស់សង្គមទាំងមូល។

**ភាគីពាក់ព័ន្ធ** (Stakeholders) (នៅក្នុងឧស្សាហកម្មនិស្សារណកម្ម): សមាជិករដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន ដែលពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម។

**ការធ្វើរ៉ែលើផ្ទៃរាប ឬលើផ្ទៃដី** (Strip Mining or Surface Mining): ប្រភេទនៃការធ្វើរ៉ែ ដែលរ៉ែត្រូវកាយចេញពីផ្ទៃដី ដោយជាដំបូង ត្រូវកាយយកចេញនូវស្រទាប់ខាងលើនៃដី ឬសិលា(បន្ទុកខាងលើ)។ ការប្រើរបៀបធ្វើរ៉ែនេះ ដើម្បីធ្វើធ្យូងថ្ម ឬខ្សាច់កៅស៊ូក្រាលថ្នល់។ ការធ្វើរ៉ែលើផ្ទៃរាប អាចធ្វើទៅបានតែក្នុងករណីដែលបណ្តុំរ៉ែដែលត្រូវកាយចេញនោះស្ថិតនៅជិតនឹងផ្ទៃដីខាងលើប៉ុណ្ណោះ។ការធ្វើរ៉ែលើផ្ទៃរាបភាគច្រើនមានទំហំធំ និងបំផ្លិចបំផ្លាញបរិស្ថានព្រមទាំងមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើភូមិសាស្ត្រ រុក្ខជាតិ ជីវចម្រុះ និងធនធានទឹក។ ក្នុងករណីមិនអាចស្តារឡើងវិញបាន ការធ្វើរ៉ែលើផ្ទៃដី បណ្តាលឲ្យកើតមានជាតំបន់សំណល់សិលាឥតជីជាតិដ៏ធំ។

**ការកៀបអណ្តូងរ៉ែ** (Squeezing a Well): ជាបច្ចេកទេសមួយ ដែលតាមរយៈនេះគេប្រើស៊ីម៉ងទៅបិទ ផ្នែកណាមួយនៃអណ្តូងរ៉ែ ដែលកើតមានការលិច ឬការជ្រាបចូលនៃទឹក ឬឧស្ម័ន។

**ការបាក់ស្រុត** (Subsidence): គឺជាលិចចុះបន្តិចម្តងៗ ឬជួនកាល គឺជាកាបាក់ធ្លាក់ភ្លាមៗនៃសិលា និងស្រទាប់ដីចូលទៅក្នុងអណ្តូងរ៉ែក្រោមដី ឬតាមបណ្តោយច្រាំងទន្លេ ឬច្រាំងសមុទ្រ។ ការបាក់ស្រុតអាចកើតមានឡើងជាធម្មជាតិ ឬទាក់ទងនឹងសកម្មភាពមនុស្ស ដូចជាការបូមខ្សាច់ និងកាយក្រោមដីជាដើម។ រចនាសម្ព័ន្ធ និងស្ថានភាពលើដៃអាចនឹងប៉ះពាល់។

# T

**អាងសំណល់រ៉ែ/ទំនប់សំណល់រ៉ែ** (Tailings Ponds/Dam): ទំនប់ ឬអាងសិប្បនិម្មិតដែលគេសាងសង់ឡើង ដើម្បីរក្សាទុកសំណល់រាវ/ឧស្ម័នពុល និងទឹកមានជាតិពុល ដែលសល់ពីការកែច្នៃរ៉ែនៅការដ្ឋានរ៉ែ។ លោហធាតុធ្ងន់ៗនៅក្នុងសំណល់រ៉ែ ជារឿយៗលិចពីកន្លែងស្តុកចូលទៅក្នុងដី និងប្រព័ន្ធផ្ទៃរងទឹកភ្លៀងដែលនៅជុំវិញ។

**ខ្សាច់កៅស៊ូក្រាលថ្នល់ និងខ្សាច់ប្រេង** (Tar Sands or Oil Sands): ជាស្រទាប់តេលាសិលាមានលក្ខណៈខុសប្លែកពីធម្មតា មានទម្រង់ជាកាកប្រេង ឬ □កៅស៊ូក្រាលថ្នល់□នៅក្នុងខ្សាច់។តេលាសិលានេះមានសភាពខាប់និងអន្ទិលៗឬ□ស្អិត□ និងពិបាកយកចេញពីខ្សាច់។ រហូតមកដល់ពេលថ្មីៗនេះ ការធ្វើរ៉ែខ្សាច់កៅស៊ូក្រាលថ្នល់ត្រូវចាត់ទុកថា មានការពិបាកចំណាយច្រើន និងបំផ្លិចបំផ្លាញបរិស្ថាន។ ដោយសារមានតម្រូវការខ្ពស់ចំពោះ ប្រេង និងបរិមាណផ្គត់ផ្គង់ថយចុះនោះ បច្ចុប្បន្ននេះ ខ្សាច់ កៅស៊ូក្រាលថ្នល់ ត្រូវបានគេកែច្នៃយកប្រេង ដោយបង្កការខូចខាតដល់បរិស្ថានយ៉ាងខ្លាំង។ ប្រតិបត្តិការធ្វើរ៉ែរបៀបនេះ ធំៗមាននៅក្នុងប្រទេសកាណាដា។ មានចលនាដ៏ធំមួយប្រឆាំងនឹងការធ្វើរ៉ែខ្សាច់កៅស៊ូក្រាលថ្នល់។

**ចំណត** (Terminal): បរិក្ខារនៅលើដីគោកដែលទទួល និងស្តុកទុកប្រេងឆៅ ព្រមទាំងផលិតផលដទៃទៀតពីកន្លែងផលិតប្រេងនៅក្នុងសមុទ្រ។

**ឧណ្ហារង្វាស់** (Therm): ខ្នាតរង្វាស់កម្តៅ ស្មើនឹង 100, 000 BTU ( ខ្នាតកម្តៅចក្រភពអង់គ្លេស/British Thermal Unit)។

**តូរីយ៉ូម**(Thorium): លោហធាតុមានវិទ្យុសកម្មពណ៌ប្រាក់លាយស យកចេញពីរ៉ែម៉ូណាហ្សិត (ហ្វូស្វាតពណ៌ត្នោតក្រហមៗ មានផ្ទុករ៉ែដីដ៏កម្រ)។ គេប្រើលោហធាតុនេះ នៅក្នុងសំលោហៈម៉ាញេស្យូមសម្រាប់ម៉ាស៊ីនយន្តហោះ ស្រទាប់ខ្សែភ្លើងនៅក្នុងម៉ាស៊ីនរេអាកទ័រ និងឥន្ធនៈនុយក្លេអ៊ែរ។ គេក៏ប្រើលោហធាតុនេះដើម្បីកំណត់អាយុកាលនៃផូស៊ីលផងដែរ។ គេអាចបន្ថែមលោហធាតុនេះទៅក្នុងកញ្ចក់ និងសេរ៉ាមិក ដើម្បីការពារកម្តៅ។

**ទីតានីញ៉ូម** (Titanium): លោហធាតុរឹងមាំ មានដង់ស៊ីតេទាបធន់នឹងរឹងច្រិះស៊ីបានខ្លាំងមានពណ៌សថ្លា កើតមានឡើងជាទូទៅនៅក្នុងសិលាកំអែភ្នំភ្លើង។ ក្នុងនាមជាសំលោហៈ ទីតានីញ៉ូម ត្រូវបានគេប្រើសម្រាប់យន្តហោះ និងយានអវកាស នាវាកាំជ្រួច នាវាមុជទឹក គ្រឿងផ្សំនៃរោងចក្រផលិតត្រី និងចម្រាញ់អំបិល។ វាក៏ត្រូវគេប្រើផងដែរ នៅក្នុងផលិតផលកីឡាជាលោហៈរូបចម្លាក់ និងឧបករណ៍វះកាត់។ ក្នុងតួនាទីជាជាតិពណ៌ ទីតានីញ៉ូម ត្រូវគេប្រើនៅក្នុងថ្នាំលាប ក្រដាស់ ថ្នាំដុសធ្មេញ ប្លាស្ទិក និងអេក្រង់ការពារពន្លឺថ្ងៃ។

**ប័ណ្ណកម្មសិទ្ធិ** (Title): ឯកសារបញ្ជាក់កម្មសិទ្ធិលើដីធ្លី ក៏អាចសំដៅទៅរកសិទ្ធិផ្តាច់មុខដើម្បីធ្វើការងារជាក់លាក់នៅក្នុងតំបន់ណាមួយជាក់លាក់ ដូចជាប័ណ្ណសិទ្ធិរុករករ៉ែជាដើម។

**អ្នកកាន់កាប់ប័ណ្ណកម្មសិទ្ធិ** (Title Holder): ក្រុមហ៊ុន ឬអង្គភាពដទៃទៀត ដែលកាន់កាប់ឯកសារបញ្ជាក់កម្មសិទ្ធិ ឬសិទ្ធិដទៃទៀត។

**តម្លាភាព** (Transparency): លក្ខខណ្ឌបើកចំហ និងឥតលាក់លៀម យន្តការលើកស្ទួយគណនេយ្យភាព តាមរយៈការបើកបង្ហាញព័ត៌មានទាន់ពេលវេលាត្រឹមត្រូវ និងទូលំទូលាយជាសាធារណៈ ពាក់ព័ន្ធនឹងលទ្ធផលនៃការសម្រេចចិត្តរបស់ទីភ្នាក់ងាររដ្ឋាភិបាល និងក្រុមហ៊ុននិស្សារណកម្ម។ គោលការណ៍តម្លាភាព មានវិសាលភាពហួសពីការផ្តល់ហេតុការណ៍ និងតួលេខជាមូលដ្ឋាន ព្រមទាំងរាប់បញ្ចូលទាំងយន្តការ និងដំណើរការដែលគេប្រើដើម្បីធ្វើការសម្រេចចិត្តផងដែរ។

**តោន** (Ton): ពាក្យកាត់ ឬខ្នាតរង្វាស់ជាតោនសុទ្ធ ស្មើនឹង២០.០០ផោន ខ្នាតរង្វាស់ឡុង ឬចក្រភពអង់គ្លេស គឺ២.២៤០ផោន តោនម៉ែត្រ គឺប្រមាណជា២.២០៥ផោន។

# U

**ឧស្ម័នដាច់ដោយឡែក** (Unassociated Gas): ឧស្ម័នធម្មជាតិដែលកើតឡើងដោយឯកឯងមិនស្ថិតនៅក្នុងល្បាយ ឬឧស្ម័នសេរី ដែលមានប្រេង ឬកំណរ៉ែ។

**អណ្តូងរ៉ែក្រោមដី** (Underground Mine): ប្រភេទរ៉ែ ដែលតាមរយៈនេះ គេអាចចូលទៅដល់រ៉ែ តាមរយៈរូងអណ្តូងរ៉ែ ដែលបានយកចេញដោយកម្លាំងមេកានិក ពីជម្រៅរាប់រយហ្វីតនៅក្រោមដី រួចហើយផ្ទេរមកកាន់ផ្ទៃលើនៃផែនដី តាមរយៈយានដឹកជញ្ជូន។ ហៅម្យ៉ាងទៀតថា រ៉ែ □ជ្រៅ□ ។

**ការយករ៉ែក្រោមដី** (Underground mining): ការជីកចូលទៅក្នុងដីរួចហើយធ្វើផ្លូវក្រោមដី និងរូងដើម្បីយករ៉ែចេញ។ ជួនកាលការធ្វើរ៉ែក្រោមដី អាចធ្វើឡើងយ៉ាងជ្រៅនៅក្រោមដី។

**ប្រតិបត្តិការផ្នែកខាងលើ** (Upstream): ជាប្រតិបត្តិការផ្នែកមួយនៃផ្នែកសំខាន់ៗ

ទាំងបីនៃប្រតិបត្តិការផលិតប្រេង និងឧស្ម័ន (ផ្នែកផ្សេងទៀត គឺផ្នែកកណ្តាល និងផ្នែកខាងក្រោម)។ ប្រតិបត្តិការផ្នែកខាងលើ ផ្តោតលើការរាវរក និងការផលិត និងរាប់បញ្ចូលការស្វែងរកវាលប្រេង និងឧស្ម័នក្រោមដី ឬក្រោមទឹក ការខួងអណ្តូងរុករករ៉ែ និងបន្ទាប់មកធ្វើប្រតិបត្តិការអណ្តូង ដែលរកឃើញ និងនាំយកប្រេងឆៅ និង/ឬឧស្ម័នធម្មជាតិឆៅមកកាន់ផ្ទៃខាងលើនៃផែនដី។ សូមមើលពាក្យប្រតិបត្តិការផ្នែកកណ្តាល និងផ្នែកខាងក្រោមផងដែរ)។

# V

**សរសៃរ៉ែ** (Vein): ស្រទាប់មានលក្ខណៈខុសប្លែកពីគេ ដូចនឹងតួរ៉ែមានសភាពក្រោមនៅក្នុង សិលា។ សរសៃរ៉ែកើតឡើងនៅពេលសមាសភាគរ៉ែ ដែលពាំនាំដោយទឹកនៅក្នុងសិលា តាមរយៈកំណា។ លទ្ធផលគឺការកកើតកំហាប់នៃរ៉ែលោហៈមួយដែលមានការវិវឌ្ឍជាទៀងទាត់ច្រើន ឬតិច នៃប្រវែង ទំហំ និងកម្ពស់។ នៅពេលសរសៃរ៉ែមានផ្ទុកលោហធាតុគេហៅវាថាស្រទាប់រ៉ែមានតម្លៃ( សូមមើលពាក្យ□ស្រទាប់រ៉ែមានតម្លៃ/lode□ ផងដែរ)។

**បំពង់បង្ហុយ** (Vent): ប្រព័ន្ធបញ្ចេញឧស្ម័នសុវត្ថិភាព ដើម្បីបញ្ចៀសសម្ពាធលើសមានគ្រោះថ្នាក់ដែលផ្តុំឡើង ដូចជានៅក្នុងអណ្តូងរ៉ែ ជាដើម។

**ភាពខាប់** (Viscosity): សមត្ថភាពលំហូររបស់វត្ថុរាវនៅក្នុងកម្រិតសីតុណ្ហភាពមួយ។

**ភាពហើរ ឬហួត**(Volatility): សមត្ថភាពហើរ ឬហួតរបស់វត្ថុរាវ។

# W

**អណ្តូងរ៉ែ** (Well): រន្ធដែលគេខួងក្រោមដី សម្រាប់រុករក និងប្រតិបត្តិការប្រេង។ ក្នុងន័យទូលាយ វាជាបរិធានដែលគេប្រើប្រាស់សម្រាប់បម្រើគោលបំណងរុករក និងប្រតិបត្តិការប្រេង។

**ការធ្វើរ៉ែក្នុងអណ្តូង**(WellMining): គឺជាដំណើរការកាយដីដែលមានការជីកអណ្តូង និងធ្វើកែងទ្រធ្វើពីសំណប៉ាហាំងដែលគេប្រើរទេះដើម្បីអូសខ្សាច់ចេញពីអណ្តូង។

**អណ្ដូងប្រថុយប្រថាន** (Wildcat): គឺជាអណ្ដូងប្រេង ឬឧស្ម័នធម្មជាតិ ដែលគេខួងដោយស្មានៗ នៅក្នុងតំបន់ដែលមិនដឹងថាផ្ដល់ផល ឬយ៉ាងណា។

**អង្គការពាណិជ្ជកម្មពិភពលោក** (World Trade Organization/WTO): បង្កើតឡើងនៅឆ្នាំ ១៩៩៥ WTO គឺជាអង្គការពាណិជ្ជកម្មពហុភាគី ដែលរៀបចំឡើងដើម្បីត្រួតពិនិត្យ និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មអន្តរជាតិ។ អង្គការនេះ ធ្វើការទាក់ទងនឹងការរៀបចំបញ្ញត្តិពាណិជ្ជកម្មរវាងប្រទេសចូលរួម។ វាផ្ដល់ជាក្របខណ្ឌសម្រាប់ចរចារ និងរៀបចំកិច្ចព្រមព្រៀងពណិជ្ជកម្ម និងដំណើរការដោះស្រាយវិវាទ ក្នុងគោលបំណងជំរុញប្រទេសចូលរួមឲ្យគោរពតាមកិច្ចព្រមព្រៀង WTO ដែលបានចុះកិច្ចសន្យាដោយតំណាងរបស់រដ្ឋាភិបាលជាសមាជិក និងបានផ្ដល់សច្ចាប័នដោយរដ្ឋសភារបស់ខ្លួន។ WTO មានសមាជិកចំនួន១៥៣ តំណាងឲ្យ ៩៧%នៃពាណិជ្ជកម្មពិភពលោកទាំងមូល និងមានមូលដ្ឋាននៅក្រុងហ្សឺណែវ ប្រទេសស្វីស។

# Z

**ត្បូងថៃ** (Zircon): រ៉ែដ៏សាមញ្ញ រឹង មានពណ៌ពីត្នោត ដល់គ្មានពណ៌ ដែលនៅពេលកម្ដៅ កាត់ និងខាត់ឲ្យរលោង ក្លាយជាត្បូងមានពណ៌ខៀវ ស ដ៏ប្រណិត។ ត្បូងថៃត្រូវគេប្រើប្រាស់ នៅក្នុងវត្ថុរឹង និងធ្វើជាត្បូងថ្មក្លែងក្លាយ ព្រមទាំងប្រើនៅក្នុងសេរ៉ាមិកលំអផងដែរ។

**ឯកសារយោង:**


១. បណ្ដាញនារីអន្តរជាតិ និងអាជីវកម្មរ៉ែ (International Woman and Mining Network)/Red Internacional Mujeres Y Mineria (RIMM), ខែមិនា ឆ្នាំ២០១០ ក្នុងអត្ថបទដែលមានចំណងជើងថា ស្ត្រីបង្កើតសហគមន៍រងគ្រោះដោយអាជីកម្មរ៉ែ និយាយអំពី ការការពារដីធ្លី ជីវិត និងសេចក្ដីថ្លៃថ្នូរ នៅប្រទេសឥណ្ឌា។

២. សន្ទានុក្រមនៃពាក្យដែលប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម នៅប្រទេសនីហ្សេរីយ៉ា, Coliation for Change, ២០១០។

៣. វចនានុក្រមនៃពាក្យបរិស្ថានរបស់ក្រសួងបរិស្ថានភ្នំពេញ ឆ្នាំ១៩៩៨។







គាំទ្របច្ចេកទេស & ថវិកាដោយ:

CANADIAN CATHOLIC ORGANIZATION FOR Development and Peace

MISEREOR IHR HILFSWERK

TRÓCAIRE Working for a Just World

UNDP Empowered lives. Resilient nations.

NORWEGIAN PEOPLE'S AID

Oxfam


**Contact US!**

**Extractive Industry Social and Environmental Impact (EISEI) Network**

**C/o Development and Partnership in Action (DPA)**

#69z, St 450, Toul Tompoung II, Chamkar Morn, Phnom Penh

Phone: 023 216 495/ 023 216 396

Email: eiseicoordinator@gmail.com and eiseiasstcoordinator@gmail.com

Website: www.dpacam.org